ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ត្រីមាសទី១ ឆ្នាំ២០២២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក
ស
វ




E
C
O
S
O
C
C

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
www.ecosocc.gov.kh
info@ecosocc.kh
(855) 012 915 577 (855) 012 912 009

# គតិបណ្ឌិតតេជោយុទ្ធិកសន្តិភាពនិមិត្តរូបសម្រាប់សកលលោក

« គ្មានសន្តិភាព គ្មានក្តីសង្ឃឹម គ្មានការអភិវឌ្ឍ
គ្មានការគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ »

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
សេអ៊ូល ថ្ងៃទី១២ - ០២ - ២០២២

**ក្រុមការងារព្រឹត្តិបត្រ**

នាយកគ្រប់គ្រង

- យឹម ណុលសន

និពន្ធនាយក

- អ៊ីវ ចុង

ការិយាល័យនិពន្ធ

- នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត

- លី គឹមសុខ

- ឆយ អូន

- ទីប្រឹក្សាបច្ចេកទេស

- សមាជិក-សមាជិកា នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌

អ្នកចាត់ចែងផលិត

- ប៉ិច សុខា

- អ៊ិន គុលា

អ្នកចែកផ្សាយ

- អៀង រដ្ឋា

- សេក វុទ្ធី

ការីកុំព្យូទ័រ

- អេង រត្នមុនី

- សយ វាស្នា

- យឹម ច័ន្ទតារា

# មាតិកា

ទំព័រ


I- បទអត្ថាធិប្បាយ បញ្ហាទន់ខ្សោយ អភិវឌ្ឍន៍ និងការអប់រំ ១-៣

II- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា ៤

III- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌កម្ពុជា ប្រចាំឆ្នាំ២០២១ ៥-១១

IV- បទវិភាគ៖

១- វិបត្តិនយោបាយរវាង Russia ទល់នឹង Ukraine ១២-១៤

២- សម្តេចតេជោ ហ៊ុន សែន ទៅកាន់មីយ៉ាន់ម៉ា ដើម្បីលើកទង់អាស៊ានឲ្យគ្រប់១០ឡើងវិញ ១៥

V- នាទីសិក្សា

- ពីវត្តភ្នំដូនពេញទៅជាក្រុងភ្នំពេញ រាជធានីនៃព្រះរាជាណាចក្រកម្ពុជា ១៦-២៣

VI- នាទីវប្បធម៌

១- បច្ចេកសព្ទប្រវត្តិវិទ្យា ២៤-២៥

២- ស្វែងយល់ពីប្រវត្តិមនុស្សខ្មែរ ២៦-២៩

VII- នាទីកំណាព្យ

- ជីវភាពមនុស្ស (ពាក្យ៧) ៣០

VIII- នាទីកំសាន្ត

- រឿងកំណើតស្រូវ (ទេវកថា) ៣១

# បញ្ហាទន់ខ្សោយ អភិវឌ្ឍន៍ និងការអប់រំ

គេតែងនិយាយស្ទើរគ្រប់មាត់ពីភាពទន់ខ្សោយរបស់ប្រទេសអាហ្វ្រិក-អាស៊ី។តែអ្នកខ្លះនៅពុំទាន់យល់ឱ្យបានច្បាស់លាស់អំពីលក្ខណៈនិងបញ្ហាទន់ខ្សោយនៃប្រទេសទាំងនោះទេ។ដូចនេះចម្លុះមើលជាថ្មីម្តងទៀតជាការប្រសើរម្យ៉ាង អាចឱ្យយើងយល់ជម្រៅបញ្ហាកាន់តែច្បាស់ ក្នុងគោលដៅទាញយកមេរៀនខ្លះៗ សម្រាប់ប្រទេសខ្មែរយើងដែលជាប្រទេសមួយ ក្នុងចំណោមប្រទេសទន់ខ្សោយទាំងឡាយដែរ។

តាមការសិក្សារបស់អ្នកស្រាវជ្រាវខ្លះ ប្រទេសទន់ខ្សោយមានបីបែបៈ

ទី១-ភាពទន់ខ្សោយផ្នែកបច្ចេកទេស (ប្រទេសអេស្ប៉ាញ-យូគោស្លាវី)

ទី២-ភាពទន់ខ្សោយផ្នែកសេដ្ឋកិច្ច(គឺប្រទេសដែលមានសម្បត្តិធម្មជាតិច្រើនតែនៅខ្វះការចម្រើនក្នុងវិស័យបច្ចេកទេស ដើម្បីទាញយកផលឲ្យបានច្រើន និងខ្វះមូលធនបរទេស ក្នុងការធ្វើ វិនិយោគ)

ទី៣-ចំណែកឯភូមិភាគខាងអាស៊ី ច្រើនមានភាពទន់ខ្សោយផ្នែកថាមពលមនុស្ស (potentiel humain)[១]។

ភាពទន់ខ្សោយបែបទី១ជាការស្រួលកែ។ ប្រទេសអឺរ៉ុបក្រោយសង្គ្រាមលោកលើកទី២ សុទ្ធសឹងតែនៅក្នុងស្ថានភាពបែបនេះ តែដោយបានជំនួយអំពីស.រ.អា.តាមគម្រោងការម៉ាសាល ប្រទេសអស់ទាំងនោះក៏រីកចម្រើនឡើងវិញយ៉ាងឆាប់រហ័ស។

ប្រទេសដែលជួបប្រទះនឹងស្ថានភាពទី២ ច្រើនជាប្រទេសធ្លាប់ត្រូវអាណានិគមនិយមជិះជាន់។ គេទម្លាក់កំហុសទាំងស្រុង ទៅលើពួកអតីតអាណាព្យាបាលថា បានបន្សល់ទុកឱ្យពួកគេនូវវិបត្តិបែបនេះ ហេតុដូចនេះ ពួកជាប់ចោទទាំងនោះត្រូវ«សងជំងឺចិត្ត»ទៅដើមចោទជាការចាំបាច់។ ទម្លាប់និងផ្នត់គំនិតបែបនេះមានផលវិបាកធ្ងន់ៗខ្លះដែលយើងគួរចៀសវាង។ ពួកគេយល់ថា ដើម្បីឱ្យសេដ្ឋកិច្ច«ចេញដំណើរទៅបាន» គេត្រូវ«បូមបញ្ចូលលុយ»ដាក់ក្នុងនោះឱ្យបានច្រើនជាទីបំផុត ឧបមាដូចជាគេបូមសាំងបញ្ចូលក្នុងម៉ាស៊ីនដូច្នេះដែរ។ ភារៈអ្នកផ្តល់លុយត្រូវធ្លាក់ទៅលើ «ថៅហ្វាយចាស់» ពិតប្រាកដ។ ការណ៍ដែលគេចេះតែទម្លាក់កំហុសទៅលើ«ពួកមុន»(ពួកអាណានិគម) ថាជាបុព្វហេតុនៃវិបត្តិ បណ្តាលឱ្យអ្នកដែលជាម្ចាស់ស្រុកពុំមានស្មារតីទទួលខុសត្រូវចំពោះវាសនាប្រទេសខ្លួន ដោយខិតខំរកលេសក្នុងគោលបំណងយក«រួចខ្លួន»។ អ្នកដឹកនាំប្រទេសខ្មែរយើងភាគច្រើន តែងតែប្រព្រឹត្តតាមរបៀបនេះជានិច្ច។ កាលជំនាន់សង្គមរាស្ត្រនិយមស្រុកដើរពុំលឿន គេចោទបារាំង។ សម័យកម្ពុជាប្រជាធិបតេយ្យនេះទៀតស្រុកទ្រុឌទ្រោម លិចអណ្តែតៗ គេចោទ «ពួកមុន»។

ប៉ុន្តែយើងក៏យល់ព្រមដែរថាការរើបម្រះខ្លួនចេញពីភាពទន់ខ្សោយត្រូវការពេលវេលាច្រើន។ជប៉ុនប្រើពេលអស់មួយសតវត្សទើបបានរុងរឿង។ ជំនឿចំពោះមធ្យោបាយសក្តិសិទ្ធិអស្ចារ្យ(solution miracle) នោះពុំមានឡើយ។គេពុំត្រូវយល់ថាជំងឺទន់ខ្សោយអាចជាបានភ្លាមយ៉ាងឆាប់រហ័យដូចគេលេបប៉ារ៉ាសេតាម៉ុលបាត់ក្តៅខ្លួនភ្លាមនោះទេ។ មានតែការព្យាយាមតស៊ូដោយឆន្ទៈមោះមុតទេ ទើបអាចសម្រេចគោលបំណងបាន។

ម្យ៉ាងទៀតការជួយខ្លួនឯង ជាករណីយកិច្ចរបស់ប្រទេសទន់ខ្សោយនីមួយៗ។ ជំនួយដ៏សន្ធឹកសន្ធាប់ជ្រុលហួសអាចក្លាយទៅជាការពន្លិចសេដ្ឋកិច្ចរបស់ខ្លួនក៏មានដែរ។ការរំពឹងតែទៅលើជំនួយបរទេសបណ្តាលឱ្យមានវិបត្តិមួយបែបទៀត គឺបើប្រទេសធំៗ គេមាន វិបត្តិសេដ្ឋកិច្ច ប្រទេសតូចៗក៏ទទួលរងគ្រោះវិបត្តិនឹងគេដែរ។ នៅពេលដែលសេដ្ឋកិច្ចស.រ.អា. ត្រូវរអាក់រអួលនាឆ្នាំ១៩៥៧-៥៨ប្រទេសអាស៊ីជាច្រើន ត្រូវខាតលុយអស់៤កោដិដុល្លាលើវត្ថុធាតុដើម ដែលខ្លួននាំចេញ។ ក្នុងពេលនោះការដកថយនៃទាហានអាមេរិកាំង និងវិបត្តិប្រាក់ដុល្លា បានធ្វើឱ្យរង្គោះរង្គើដល់សេដ្ឋកិច្ចភូមិភាគអាស៊ីភាគអាគ្នេយ៍ជាខ្លាំង[២]។

ដោយឃើញដូចនេះហើយ ទើបអ្នកនិពន្ធការសែតម្នាក់សរសេរថា«កាលណាប្រទេសធំៗគ្រាន់តែឈឺផ្ដាសសាយ ប្រទេសតូចៗមុខជាត្រូវគ្រុនពិតប្រាកដ...»(Lorsque les pays avancés attrappent une rhume, les pays sous-développés font une pneumonie... )។

ដើម្បីកុំឱ្យប្រទេសខ្មែរយើងជួបប្រទះនឹងវិបត្តិនេះខ្លាំងពេក យើងត្រូវរៀបចំគម្រោងការអភិវឌ្ឍន៍ផ្អែកទៅលើមូលដ្ឋានសំខាន់របស់ប្រទេសយើង គឺកសិកម្មនេះឯង។ យើងពុំយល់ស្របទេ ចំពោះមតិដែលឱ្យតម្លៃទៅលើឧស្សាហកម្មថាជាមធ្យោបាយសក្តិសិទ្ធិអស្ចារ្យ អាចស្ទួយប្រទេសទន់ខ្សោយចេញអំពីការយឺតយ៉ាវបាន ។ ចូរយើងសង្កេតមើលឱ្យបានល្អិតល្អន់ យើងនឹងឃើញថា ប្រទេសមហាអំណាចសេដ្ឋកិច្ចសព្វថ្ងៃ សុទ្ធតែ«ចេញដំណើរ» ដោយកសិកម្មទាំងអស់ (ស.រ.អា. ចិន រុស្ស៊ី បារាំង អាល្លឺម៉ាញ កាណាដា អូស្ត្រាលី នូវែលហ្សេឡង់ អាហ្សង់ទីន...)។

កសិកម្មក្ដី ឧស្សាហកម្មក្ដី អាចរីកស្គុះស្គាយបានក៏ដោយសារមនុស្សដែរ។ កត្តាមនុស្ស ជាកត្តាសំខាន់បំផុតក្នុងការលូតលាស់។ ប្រទេសទន់ខ្សោយក្នុងស្ថានភាពទី៣ ដែលមានប្រជាជន ពុំសូវចេះដឹងសម្រេចការអ្វីក៏ពុំបានចម្រើន។ មនុស្សប្រទេសស្វីស អាចយកដែកមួយដុំធ្វើឱ្យទៅជារ៉ឺស័រនាឡិកាថ្លៃរាប់ម៉ឺនរៀល ចំណែកឯមនុស្សប្រទេសទន់ខ្សោយអាចយកដែកមួយដុំធ្វើត្រឹមតែដែកគោលថ្លៃថោកបំផុត។ការណ៍មួយដែលរឹតតែបញ្ជាក់អំពីតម្លៃនៃកត្តាមនុស្សនោះគឺប្រទេសទន់ខ្សោយខ្លាំងពុំអាចទទួលជំនួយនោះឱ្យបានលទ្ធផលល្អប្រសើរ។

បន្ទាប់ពីសង្គ្រាមលោកលើកទី២ ក្រោមគម្រោងការម៉ាសាល ប្រទេសអឺរ៉ុប អាចទាញយកប្រយោជន៍ពីជំនួយអាមេរិកាំង ក្នុងមួយឆ្នាំៗរហូតដល់ឆ្នាំ១៩៧០ នេះដោយសារគេមានអ្នកបច្ចេកទេស យន្តការី វិស្វករប៉ិនប្រសប់។ ផ្ទុយទៅវិញប្រទេសទន់ខ្សោយ អាចទាញប្រយោជន៍ខ្លាំងណាស់ ត្រឹមតែ៣០%ប៉ុណ្ណោះ[៣]។ ការពុំព្រមដោះស្រាយបញ្ហាកសិកម្មឱ្យដល់«ជម្រៅ» ការពុំរៀប ចំកម្មវិធីមួយបន្ថយការខុសគ្នាឆ្ងាយពេក រវាងប្រាក់ចំណូលនៃអ្នកក្រនិងអ្នកមាន ការពុំគិតពីកត្តាមនុស្ស ការពុំគិតពីកត្តាសង្គម កង្វះការសិក្សាឱ្យបានម៉ត់ចត់ ក្នុងការធ្វើវិនិយោគគ្រប់ផ្នែកសេដ្ឋកិច្ច ភាគរយស្ដួចស្ដើងក្នុងការចំណាយសម្រាប់ពង្រីកកសិកម្ម ដែលចិញ្ចឹមមនុស្សភាគច្រើន ទាំងនេះហើយជាឧបសគ្គក្នុងការអភិវឌ្ឍ[៤]។

ចុះចំណែកការសិក្សាផ្នែកឧត្តមសិក្សា ត្រូវបន្ស៊ីដូចម្ដេចឱ្យស្របទៅតាមការ ត្រូវការរបស់សេដ្ឋកិច្ច និងសង្គមយើង។

ក្នុងគោលបំណងឱ្យការសិក្សាមានផលល្អ យើងត្រូវហ៊ានកែប្រែកម្មវិធីសិក្សាយើងខ្លះ ដោយធ្វើយ៉ាងដូចម្ដេចឲ្យមុខវិជ្ជាដែលនិស្សិតរៀន ជាប់ប្រទាក់ប្រទងនឹងបញ្ហាសង្គមរបស់យើង។ យើងសង្កេតឃើញថា អ្នកដែលរៀនច្រើនដាច់ចេញពីពិភពដែលខ្លួនរស់នៅ ពុំស្គាល់ចំណោទបញ្ហាដែលចោទមកក្នុងសង្គម។ អ្នករៀនអក្សរសិល្ប៍ក៏ភ្លេចខ្លួនក្នុងអក្សរសិល្ប៍ទៅ អ្នករៀនច្បាប់ក៏លង់ទ្រនេសក្នុងច្បាប់បរទេសទៅ។ អ្នកសិក្សាផ្នែកពេទ្យ ពុំខិតខំស្រាវជ្រាវរក ថ្នាំខ្មែរដែលមានវត្ថុធាតុដើម នៅក្នុងស្រុក...។ម្យ៉ាងទៀត និស្សិតដែលចេញពីមហាវិទ្យាល័យនីមួយៗ ហាក់ដូចជាទៅដោះស្រាយ បញ្ហាសង្គមតែក្នុងប៉ុយរ៉ូសោះ គេពុំបានជ្រៀតខ្លួនចូលទៅក្នុងសរសៃសង្គមឡើយ។

យើងឃើញថា យើងខ្វះអ្នកតិចនិកផ្នែកទឹក វិស្វករកសិកម្ម ពេទ្យសត្វដែលបម្រើរាស្ត្រពិតប្រាកដ អន់ជាងនេះទៅទៀតយើងគ្មានភ្នាក់ងារបច្ចេកទេសឬកម្មករដែលស្ទាត់ជំនាញឡើយ។ព្រោះហេតុនេះហើយបានជាលោក ភោគ ឆាយ ពោលថា « គឺគ្មានបានការអ្វីទេ ដែលយើងបញ្ចេញវិស្វករ អ្នកអប់រំ ភ្នាក់ងារកសិកម្មទាំងរយ ទាំងពាន់ ប្រសិនបើពួកអស់នោះ គ្មានសមត្ថភាពនឹងជួយបង្កើនផលកសិកម្ម ប្រសិនបើហ្វូងប្រជា- ជន នៅតែក្ររហាម ប្រសិនបើយុវជន នៅតែដាច់ពីស្រែចម្ការដដែល »[៥]។

ក្នុងគោលបំណងឱ្យនិស្សិតមហាវិទ្យាល័យ ស្គាល់បញ្ហាសង្គម អ្នកអក្សរសាស្ត្រក្តី អ្នកបច្ចេកទេសក្តី ត្រូវចេះដឹងជាចាំបាច់នូវស្បង់នៃសង្គម( les sciences sociales, les sciences humaines )។ព្រោះសម័យយើងឥឡូវនេះវិជ្ជាស្បង់ទាំងនេះ បានត្រូវគេយកទៅបម្រើសង្គមយ៉ាងច្រើន។ យើងឃើញក្រោយសង្គ្រាមលោកលើកទី២ នៅស.រ.អា. អ្នកសិក្សាផ្នែកស្បង់នៃសង្គមមនុស្សសាស្ត្រ ត្រូវគេហៅរកទៅជួយកសិកម្ម ឧស្សាហកម្ម រហូតដល់មហាវិទ្យាល័យក្លាយទៅជាកន្លែង «លក់» អ្នកចេះដឹងទៅបម្រើប្រយោជន៍សង្គម។

រូបភាពទី១ : មុខវិជ្ជា និង បញ្ហាសង្គមពុំស៊ីគ្នា




រូបភាពទី២ : មុខវិជ្ជាដោះស្រាយបញ្ហាសង្គម




I : មុខវិជ្ជាដែលសិក្សា S : បញ្ហាសង្គម

ជាទីបញ្ចប់ យើងត្រូវតែមានសាស្ត្រាចារ្យមានចំណេះខ្ពង់ខ្ពស់ណែនាំនិស្សិតឱ្យអនុវត្តចំណេះវិជ្ជាដែលខ្លួនមាននោះ មកពិចារណាបញ្ហាសង្គម រៀនដោះស្រាយជាមួយគ្នា រហូតក្លាយទៅជាអ្នកស្គាល់ជម្រៅសង្គមពិតប្រាកដ។

ដើម្បីឱ្យយើងដើបមុខដើបមាត់បាន ត្រូវតែយើងភ្ញាក់រឭក ប្តេជ្ញាធ្វើការជូនប្រទេសជាតិ ដោយពិតប្រាកដ ដោយខិតខំអប់រំគ្នាឱ្យបានមុតមាំ។ អ្នកប្រាជ្ញបុរាណចិនម្នាក់ពោលថា៖

«បើឯងធ្វើផែនការដើម្បីមួយឆ្នាំ ចូរឯងដាំស្រូវទៅ បើឯងធ្វើផែនការដើម្បីមួយសតវត្ស ចូរឯងបង្រៀនមនុស្សឱ្យចេះដឹងឡើង»។

«Si tu fais des plans pour un an , fais du riz ; si tu fais des plans pour un siècle, instruis des hommes »។

## កម្រងទស្សនៈប្លែកៗ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ថុង

---

(១) ការចែកនេះ ធ្វើយោងទៅតាមការសិក្សារបស់លោក ប៊ែរណា ផល( Bernard Pall ) បណ្ឌិតទស្សនវិជ្ជា ហើយជាសាស្ត្រាចារ្យផ្នែកទំនាក់ទំនងអន្តរជាតិ នៅសកលវិទ្យាល័យ ហាវ៉ាដ ( Haward ) វ៉ាស៊ិនតោន ស.រ.អា.។

(២) C.E.A.E.O. Economie Survey of Asia and The Far East 1970.

(៣) Bernard Fall : De certains problèmes des pays sous développés in France-Asie. No 162-163

(៤) Patrice de Beer: La guerre et «la Révolution verte» in le Monde Diplomatique. No 213

(៥) Phouk Chhay : L´ héritage socio-économique de l´ ancien Régime in Cambodge. Nouveau N0 1

# សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា

## ដំណើរការកិច្ចប្រជុំ

សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជាត្រូវបានដាក់ឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេសនៅថ្ងៃទី១០ និង១២ ខែវិច្ឆិកា ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ Zoom រៀបចំដោយទីស្តីគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យពិភាក្សាលើទម្រង់ ខ្លឹមសារនិងអក្ខរាវិរុទ្ធ ដឹកនាំអង្គប្រជុំដោយឯកឧត្តម **សុក ផេង** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាអនុប្រធានប្រឹក្សាអ្នកច្បាប់ និងឯកឧត្តម **អ៊ុច ថោងសេង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជាសហប្រធានអង្គប្រជុំ ដោយមានការអញ្ជើញចូលរួមពី តំណាងក្រសួងពាណិជ្ជកម្មដែលជាក្រសួងសាមីរៀបចំសេចក្តីព្រាងដឹកនាំដោយឯកឧត្តម **ម៉ៅ ថូរ៉ា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាសមាជិក សមាជិកា នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ គណៈកម្មការភាសាវិទ្យាខ្មែរនិងមន្ត្រីទីស្តីគណៈរដ្ឋមន្ត្រីពាក់ព័ន្ធមួយចំនួន។

បន្ទាប់ពីឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេសរួចមក សេចក្តីព្រាងអនុក្រឹត្យនេះត្រូវបានដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនៅថ្ងៃទី៨ និង២១ ខែធ្នូ ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ Zoom ក្រោមអធិបតីភាព ឯកឧត្តម **តឹករ៉េត សំរេច** រដ្ឋមន្ត្រីអមនាយករដ្ឋមន្ត្រីនិងជារដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រីដោយមានការអញ្ជើញចូលរួមពីតំណាងគ្រប់ក្រសួងស្ថាប័នទាំងអស់ ដើម្បីពិនិត្យពិភាក្សាមុនគោរពជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

## គោលបំណងនៃសេចក្តីព្រាង

សេចក្តីព្រាងអនុក្រឹត្យនេះមានគោលបំណងជំរុញនិងលើកកម្ពស់ការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាពនិងជួយអ្នកប្រើប្រាស់ឱ្យទទួលបានទំនិញនិងសេវាមានគុណភាពខ្ពស់ថ្លៃទាបសមរម្យបែបនិងមានជម្រើសច្រើន។

## សារៈប្រយោជន៍នៃសេចក្តីព្រាង

ក- បង្កើតនូវរចនាសម្ព័ន្ធនៃស្ថាប័នប្រកួតប្រជែងថ្នាក់ជាតិមួយដែលរួមមាន៖ សមាសភាពការតែងតាំងអាណត្តិនិងការបញ្ចប់អាណត្តិសម្រាប់ទទួលបន្ទុកងនុវត្តច្បាប់ស្តីពីការប្រកួតប្រជែងដើម្បីសម្រេចឱ្យបាននូវគោលបំណងដូចមានចែងក្នុងមាត្រានៃច្បាប់ស្តីពីការប្រកួតប្រជែង។

ខ- កំណត់នូវតួនាទីនិងភារកិច្ចលម្អិតរបស់គណៈកម្មាធិការប្រកួតប្រជែង "គ.ប.ក." និងសមាជិករបស់ គ.ប.ក. ក៏ដូចជាការចាត់តាំងឱ្យអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែងនិងបង្ក្រាបការក្លែងបន្លំ "ក.ប.ប." ដើម្បីបំពេញតួនាទីជាសេនាធិការរបស់គ.ប.ក. ក្នុងការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង។

គ- កំណត់នូវយន្តការ និងរបៀបរបបការងារចាំបាច់មួយចំនួន ជាពិសេសការបង្កើតគណៈកម្មការលើករណីប្រកួតប្រជែង ដំណើរការកិច្ចប្រជុំ និងទំនាស់ផលប្រយោជន៍ដើម្បីពិនិត្យនិងដោះស្រាយលើបញ្ហាប្រកួតប្រជែង មុនឈានទៅដល់ការធ្វើសេចក្តីសម្រេចចំពោះការបំពានច្បាប់ស្តីពីការប្រកួតប្រជែងក៏ដូចជាសេចក្តីសម្រេចផ្សេងៗ។

*ក.ស.វ. - ក្រុម ២*

របាយការណ៍នេះ ត្រូវបានរៀបចំឡើងក្រោយកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ក.ស.វ.) ដើម្បីពិភាក្សាលើស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលបានប្រព្រឹត្តទៅនាថ្ងៃអង្គារ ៧កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ ក្រោមអធិបតីភាព ឯកឧត្តម **ឌុយ ឆៅ** ទីប្រឹក្សាបច្ចេកទេស តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធាន ក.ស.វ. ដែលមានសមាសភាពចូលរួម អនុប្រធានប្រចាំការ អនុប្រធានក.ស.វ. ឯកឧត្តម **សាវ៉ាត់ ខាន់** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារក.ស.វ. សមាជិក សមាជិកា ទីប្រឹក្សាបច្ចេកទេស អគ្គលេខាធិការស្តីទី អគ្គលេខាធិការរង ប្រធានផ្នែកនិងមន្ត្រីបច្ចេកទេសអគ្គលេខាធិការដ្ឋាននៃ ក.ស.វ. តាមរយៈប្រព័ន្ធហ្សូម (Zoom)។ ការវិភាគផ្អែកលើទិន្នន័យទទួលបានពីក្រសួង ស្ថាប័ន ពាក់ព័ន្ធ ព្រមទាំង មតិយោបល់ពីអង្គប្រជុំទាំងមូល។

### ១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់

➤ អតិផរណាឆ្នាំ២០២១ មានអត្រាស្មើនឹង២,៩% ក្នុងនោះក្រុមទំនិញដែលឡើងថ្លៃលើសអត្រាអតិផរណាសរុប មានសម្លៀកបំពាក់និងស្បែកជើង ការដឹកជញ្ជូន និងទំនិញនិងសេវាកម្មផ្សេងៗ។

តារាង ១.១. បម្រែបម្រួលសន្ទស្សន៍ថ្លៃតាមក្រុមទំនិញ

| ល.រ. | ក្រុមទំនិញ | អតិផរណាឆ្នាំ២០២១ | អតិផរណាឆ្នាំ២០២០ |
|---|---|---|---|
| | ទំនិញប្រើប្រាស់ (២៥៩ មុខ) | ២,៩% | ២,៩% |
| ១ | ដឹកជញ្ជូន | ៨,៨% | -៤,៥% |
| | ក្នុងនោះប្រេងសាំង | ២៦,៥% | -១៤,៨% |
| ២ | ទំនិញនិងសេវាកម្មផ្សេងៗ | ៥,២% | ៤,២% |
| ៣ | សម្លៀកបំពាក់ និងស្បែកជើង | ៤,៩% | ២,៩% |
| ៤ | ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងៗ | ២,៩% | ១,១% |
| ៥ | ម្ហូបអាហារ | ២,៨% | ៤,៧% |
| ៦ | សុខាភិបាល | ១,២% | ០,២% |
| ៧ | គ្រឿងសង្ហារឹម និងសម្ភារៈប្រើប្រាស់ | ១,០% | ០,៦% |
| ៨ | ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | ១,០% | ២,២% |
| ៩ | ភោជនីយដ្ឋាន | ០,៨% | ៣,៩% |
| ១០ | កម្សាន្ត និងវប្បធម៌ | ០,៨% | ០,៨% |
| ១១ | ការសិក្សា | ០,៣% | ២,៩% |
| ១២ | ទូរគមនាគមន៍ | -០,៣% | -០,៦% |

⇨ មុខទំនិញដែលឡើងថ្លៃគួរឲ្យកត់សម្គាល់មាន ប្រេងសាំង ២៦,៥% ប្រេងម៉ាស៊ូត ២៤,៨% និងឧស្ម័ន ១០,៤% ។

តារាង១.២. អតិផរណាប្រចាំខែ ឆ្នាំ២០១៩-២០២១ (កំណើនថ្លៃទំនិញធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០២១ | ខែដូចគ្នាឆ្នាំមុន | ២,៦% | ១,៧% | ២,១% | ២,៧% | ៣,០% | ២,៧% | ៣,៣% | ៣,៤% | ៣,០% | ២,៩% | ៣,៨% | ៣,៧% | ២,៩% |
| ២០២០ | ខែដូចគ្នាឆ្នាំមុន | ៣,៦% | ២,៧% | ២,៨% | ១,៩% | ២,៤% | ៣,២% | ៣,១% | ២,៤% | ២,៩% | ៣,៧% | ៣,៧% | ២,៩% | ២,៩% |
| ២០១៩ | ខែដូចគ្នាឆ្នាំមុន | ១,៥% | ២,០% | ២,២% | ២,១% | ២,០% | ១,៤% | ២,២% | ២,១% | ១,៧% | ១,៣% | ១,៨% | ៣,១% | ១,៩% |

➤**អត្រាប្តូរប្រាក់:**

⇨ប្រាក់រៀលមានការធ្លាក់ថ្លៃ ០,៧% ធៀបនឹងប្រាក់ដុល្លារអាមេរិក ធ្លាក់ថ្លៃ៣,២% ធៀបនឹងប្រាក់យ៉េន់ និងធ្លាក់ថ្លៃ ២,៣%ធៀបនឹងប្រាក់ដុង ប៉ុន្តែមានការឡើងថ្លៃ៩,៦%ធៀបនឹងប្រាក់បាត។ នាចុងឆ្នាំ២០២១ អត្រាប្តូរប្រាក់រៀល មានស្ថានភាពដូចខាងក្រោម:

- ▪ប្រាក់រៀលធៀបនឹងដុល្លារអាមេរិកមានអត្រា៤០៧៤រ/ដុល្លារ
- ▪ ប្រាក់រៀលធៀបនឹងដុងវៀតណាមមានអត្រា០,១៧៩រ/ដុង
- ▪ប្រាក់រៀលធៀបនឹងបាតថៃមានអត្រា១២២រ/បាត
- ▪ប្រាក់រៀលធៀបនឹងយ៉េន់ចិនមានអត្រា៦៣៩រ/យ៉េន់។

## ២. ស្ថានភាពថវិកាជាតិ

➤យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ ចំណូលថវិកាជាតិក្នុងឆ្នាំ២០២១នេះអនុវត្តបានចំនួន ២១ ២០២,៧ ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៥ ៣០០,៧លានដុល្លារ) ស្មើនឹង ១០២% នៃផែនការ ក្នុងនោះចំណូលចរន្ត ២០ ០១១,៩ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៥ ០០៣,០ លានដុល្លារ) ស្មើនឹង ១០១,៦% នៃផែនការ និងចំណូលមូលធន ១ ០៩៥,៥ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ២៧៣,៩លានដុល្លារ) ស្មើនឹង ២៤៧% នៃផែនការ ។

➤ បើធៀបនឹងឆ្នាំ២០២០ ចំណូលថវិកាជាតិថយចុះ៧,៣%ក្នុងនេះ ចំណូលចរន្តថយចុះ៤,៨% និងចំណូលមូលធន ថយចុះ៤០,៥% ។

⇨ការថយចុះនៃចំណូលចរន្តជាចម្បងបណ្តាលមកពីចំណូលសារពើពន្ធថយចុះ១២,០% និងចំណូលមិនមែនសារពើពន្ធ ថយចុះ២១,០%។

តារាង២.១. ចំណូលសារពើពន្ធ ឆ្នាំ២០២១

| មុខចំណូល | ធៀបនឹងផែនការ | %Δធៀបនឹងឆ្នាំ២០២០ | មុខចំណូល | ធៀបនឹងផែនការ | %Δធៀបនឹងឆ្នាំ២០២០ |
|---|---|---|---|---|---|
| **ចំណូលសារពើពន្ធ** * | ១០៤,៥% | -៤,៧% | **ចំណូលមិនមែនសារពើពន្ធ*** | ៧៧,៥% | -៣២,៨% |
| ✓**ពន្ធ និងអាករគយ** ** | ៩៦,២% | -៥,៧% | ✓កាស៊ីណូ | ៤,០% | -៩៥,២% |
| –ពន្ធគយ (របបនាំចូល) | — | --៤,៩% | ✓ចំណូលពីអជ្ញាបណ្ណក្នុងស្រុក | ២២៧% | +១២១,៦% |
| –អាករពិសេសលើរបបនាំចូល | — | -៣,៦% - | ✓កម្រៃការគ្រប់គ្រង និងទិដ្ឋាការនាំចេញ | ៨៦,៧% | +២៦,៦% |
| –អាករលើតម្លៃបន្ថែមរបបនាំចូល | — | -៦,៨ | ✓នេសាទ | ០,០% | -៩៩,៤% |
| –អាករនាំចេញ | — | +៨២,៨% | ✓ រុក្ខាប្រមាញ់ | ១៧០,៣% | +៦០,៦% |
| –អាករបន្ថែមលើតេលសិលា | — | -៩,៧% | ✓សម្បទានរ៉ែ | ៦៨,៨% | -១០,៨% |

| មុខចំណូល | ធៀបនឹងផែនការ | %Δធៀបនឹងឆ្នាំ២០២០ | មុខចំណូល | ធៀបនឹងផែនការ | %Δធៀបនឹងឆ្នាំ២០២០ |
|---|---|---|---|---|---|
| **✓ចំណូលពន្ធដារ ***** | ១២០,២% | -៣,៦% | ✓អាកាសចរណ៍ស៊ីវិល | ១៦,១% | -៨៤,១% |
| –ពន្ធលើប្រាក់បៀវត្ស | ១៣២,១% | +៩,២% | ✓ផលទុនទេសចរណ៍ | ១,៥% | -៩៦,៤% |
| – ពន្ធលើប្រាក់ចំណូល | ១៣៧,៧% | -២០,២% | ✓ ត្រួតពិនិត្យគុណភាពផលិតផល | ៩១,៩% | -១១,០% |
| – អាករលើតម្លៃបន្ថែម | ៨៨,៦% | -៩,៧% | ✓ ជួលរោងចក្រ សហគ្រាសសម្ភារៈ | ៨៥,៧% | +៣,៩% |
| –អាករពិសេស | ៨៣,២% | -២៥,០% | | | |
| –ពន្ធថវិកាខេត្ត-រាជធានី | ១៥៥,២% | -៣០,៧% | | | |

* តួលេខរតនាគាជាតិ  **តួលេខអគ្គនាយកដ្ឋានគយនិងរដ្ឋាករ  ***តួលេខអគ្គនាយកដ្ឋានពន្ធដារ

➢ចំណាយថវិកាជាតិក្នុងឆ្នាំ២០២១ អនុវត្តបាន ២២ ៩២០,១ ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៥ ៧៣០,០ លានដុល្លារ) ស្មើនឹង ១០៦,៦% នៃផែនការ ក្នុងនោះ ចំណាយចរន្ត ១៦ ៩៨១,៦ ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៤ ២៤៥,៤ លានដុល្លារ) ស្មើនឹង ១២២,០% នៃផែនការ និងចំណាយមូលធន ៥ ៩៣៨,៥ ប៊ីលានរៀល ស្មើនឹង ៧៨,៤% នៃផែនការ។

➢បើធៀបនឹងឆ្នាំមុន ចំណាយថវិកាជាតិកើនឡើង២,៧% ក្នុងនោះចំណាយចរន្តកើនឡើង២,៩% និងចំណាយមូលធនកើនឡើង១,៩%។

➢ជាលទ្ធផល ថវិកាជាតិនាឆ្នាំ២០២១ មានឱនភាពចំនួន ១ ៧១៧,៤ ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ៤២៩,៣ លានដុល្លារអាមេរិក)។ ប៉ុន្តែគួរកត់សម្គាល់ថាតួលេខចំណាយមូលធនក្នុងតារាងទិន្នន័យឆ្លុះបញ្ចាំងតែចំណាយដែលបានឆ្លងកាត់ រតនាគារជាតិតែប៉ុណ្ណោះ។

## ៣. ស្ថានភាពរូបិយវត្ថុ

➢សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២១មានសូចនាកររូបិយវត្ថុដូចខាងក្រោម :

⇨រូបិយវត្ថុ *M2* មានចំនួន ១៥៨ ៧៣៨,៦ ប៊ីលានរៀល កើនឡើង ១៦,៣% ធៀបនឹងឆ្នាំ២០២០។

**សមាសធាតុរូបិយវត្ថុ ឆ្នាំ២០២០** (% នៃរូបិយវត្ថុ *M2*)




**សមាសធាតុរូបិយវត្ថុ ឆ្នាំ២០២១**




តារាង៣.១. កំណើនសូចនាកររូបិយវត្ថុ ២០១៧-២០២១ ធៀបនឹងឆ្នាំមុន

| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|
| *M2* | +២៣,១% | +២៦,៦% | +១៨,២% | +១៥,៣% | +១៦,៣% |
| *សមាមាត្រ M2 ក្នុងផសស* | ៨៨,២% | ១០០,៧% | ១០៧,៧% | +១២៥,២% | +១៣៦% |

| | | | | | |
|---|---|---|---|---|---|
| *M1* | +៣៤,០% | +២២,៤% | +២៥,០% | +៩,១% | +១៥,៣% |
| *សមាមាត្រ M1 ក្នុងផសស* | ២៥,៩% | ២៨,៦% | ៣២,៤% | ៣៥,៦% | ៣៨,៣% |
| រូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ | +២៨,០% | +១០,៨% | +៣២,១% | +១៣,២% | +៨,៣% |
| ប្រាក់បញ្ញើចរន្ត | +៣៧,៣% | +២៨,៦% | +២១,៨% | +៧,០% | +១៨,៩% |
| ប្រាក់បញ្ញើផ្សេងទៀត | +១៩,៣% | +២៨,៣% | +១៥,៤% | +១៧,៩% | +១៦,៧% |
| ប្រាក់បញ្ញើជារូបិយបណ្ណ | +២៣,៨% | +៣០,២% | +១៥,៤% | +១៣,៩% | +១៥,០% |

⇨ក្នុងឆ្នាំ២០២១ រូបិយវត្ថុទូទៅ*M2*មានចំនួនប្រហែល ១៣៦,០%នៃផសស ប៉ុន្តែ**សមមាត្រ***M1*ក្នុងផសស មានត្រឹមតែ ៣៨,៣% ប៉ុណ្ណោះ។

➢ទុនបំរុងជារូបិយប័ណ្ណបរទេសសុទ្ធ មានចំនួន ២០ ២៦៥,២ លានដុល្លារថយចុះ៥,០% ធៀបនឹងឆ្នាំ ២០២០។

➢ទុនបំរុងជារូបិយប័ណ្ណបរទេសសុទ្ធខាងលើ អាចធានាការនាំចូលបានចំនួន ៨,៣ ខែ។

➢ការផ្តល់ឥណទានដោយធនាគារពាណិជ្ជមានចំនួន ១៦៤ ៥២២,៤ ប៊ីលានរៀលកើនឡើង ២៥,២%ធៀបនឹងឆ្នាំមុន។

➢ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(មិនទាន់ទទួលបានតួលេខ)

តារាង៣.២. អត្រាការប្រាក់ប្រចាំឆ្នាំ:

| *ប្រភេទអត្រាការប្រាក់* | *អត្រាឆ្នាំ*២០២១ | *អត្រាឆ្នាំ*២០២០ | %∆(២០២១/២០២០) |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៤,៨% | ៥,៣% | -១០,២% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ៩,៩% | ៩,៨% | ០,៦% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,០% | ៣,២% | ២៣,០% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៨,៤% | ៨,៥% | -០,២% |
| កម្ចីជារៀលនៅអិល អូ អិល ស៊ី | ១៧,៧% | ១៧,៨% | -១,០% |
| កម្ចីជារៀលនៅអម្រឹត | ១៨,០% | ១៧,៥% | ៣,០% |
| កម្ចីជារៀលនៅប្រាសាក់ | ១៦,៦% | ១៧,១% | -២,៨% |

## ៤. ស្ថានភាព កសិកម្ម ឧស្សាហកម្ម រ៉ែ និងថាមពល សេវាកម្ម និងវប្បធម៌

➢***កសិកម្ម:***

⇨ផលិតផលស្រូវប្រចាំឆ្នាំ២០២១ (មិនទាន់ទទួលបានតួលេខ)

⇨ក្នុងឆ្នាំ២០២១ ផលិតផលកៅស៊ូមានចំនួន៣៦៨,០ពាន់តោន កើនឡើង ៥,៤% ធៀបនឹងឆ្នាំ២០២០។ ផ្ទៃដីចៀរជ័រមានចំនួន៣១០,២ ពាន់ហិកតាកើនឡើង៦,០%ធៀបនឹងឆ្នាំ២០២០ និងផ្ទៃដីដាំដុះសរុបមាន ៤០៤,០ ពាន់ហិចតាថយចុះ ០,០១%ធៀបនឹងឆ្នាំ២០២០។

⇨ ផលិតកម្មនេសាទឆ្នាំ២០២១ មានចំនួន ៨៥៦,៤ ពាន់តោនមានការថយចុះ៨,៥% ធៀបនឹងឆ្នាំ២០២០។

➢***ឧស្សាហកម្ម***

⇨ចំនួនរោងចក្រសរុបដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្មមានចំនួន ១ ៨៧៩ រោងចក្រ កើនឡើង ០,៨%ធៀបនឹងឆ្នាំ២០២០។

⇨ **ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាស នៅក្រសួងឧស្សាហកម្ម:**

| *ប្រភេទ* | *ចំនួន :២០២១* | *ចំនួន:២០២០* | %Δ |
|---|---|---|---|
| ចំនួនរោងចក្រសរុប | ១ ៨៧៩ | ១ ៨៦៤ | - ៣០,៦% |
| រោងចក្រថ្មី ដែលបានចុះបញ្ជី | ១៦៣ | ២៣៥ | +០,៨% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | | ២៦១ | |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | | ១៧៥ | |

➢ ***រ៉ែនិងថាមពល:***

⇨ ថាមពលអគ្គិសនីផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ១២ ៨៩២,៧ GWh កើនឡើង ៥,៧% ធៀបនិងឆ្នាំ ២០២០។ ក្នុងនោះ៖

- វារីអគ្គិសនីមានចំនួន ៥ ០៤៦,៨ GWh កើនឡើង ៣០,៧% ធៀបនឹងឆ្នាំ២០២០ (ស្មើ៣៩,១%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា)
- ធ្យូងថ្មមានចំនួន ៣ ៤៥៥,៦ GWh ថយចុះ១១,៨% ធៀបនឹងឆ្នាំ២០២០ (ស្មើ២៦,៨%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា)
- ថាមពលពន្លឺព្រះអាទិត្យ (Solar) មានចំនួន ៦០៤,៤ GWh កើនឡើង ១០៥,៨% ធៀបនឹងឆ្នាំ២០២០ (ស្មើ៤,៧%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា)
- នាំចូលពីប្រទេសជិតខាងមានចំនួន ៣ ១៨៣,៩ GWh ថយចុះ១១,៣% ធៀបនឹងឆ្នាំ២០២០ (ស្មើ ២៤,៧%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា)
- និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន ៦០២,០ GWh កើនឡើង ១១,៣% ធៀបនឹងឆ្នាំ ២០២០ (ស្មើ៤,៧%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា)។

⇨ ផលិតកម្មស៊ីម៉ង់ត៍ ក្នុងឆ្នាំ២០២១ មានចំនួន ៨ ៩៤៤,៨ ពាន់តោនមានការកើនឡើង៥,២%ធៀបនឹងឆ្នាំ ២០២០។

➢ **សំណង់ (ការអនុញ្ញាត):**

| *ប្រភេទសំណង់* | ពាន់ម២ :២០២១ | ពាន់ម២ :២០២០ | % Δ |
|---|---|---|---|
| លំនៅឋាន | ៧ ៣៩៣,០ | ៧ ៥៦៧,៥ | -២,៣% |
| ឧស្សាហកម្ម | ២ ៥៤៤,៥ | ២ ៣៣៥,០ | +៩,០% |
| ពាណិជ្ជកម្ម | ២ ០៤២,២ | ៥ ៣៩៤,៧ | -៦២,១% |
| ទេសចរណ៍ | ៤១៧,៥ | ៦៥៣,២ | -៣៦,១% |
| … | … | … | … |
| អនុញ្ញាតសរុប | ១២ ៩៩៨,១ | ១៦ ៩៦៥,៨ | -២៣,៤% |

ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមឆ្នាំ ២០២១ នេះគឺសំណង់លំនៅឋាន ៥៦,៩% សំណង់ឧស្សាហកម្ម ១៩,៦% និងសំណង់ពាណិជ្ជកម្ម ១៥,៧% នៃផ្ទៃក្រឡាសរុប។

➢ **ការចុះបញ្ជីនិងលុបចេញពីបញ្ជី**

| *ប្រភេទ* | ២០២១ *(ចំនួន)* | ២០២០ (ចំនួន) | *%Δ* |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៤ ៧៤៧ | ៥ ៤៦៥ | -១៣,១% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៦១៧ | ៤៦៤ | +៣៣,០% |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៦ ៨១៤ | ៧ ២០៦ | -៥,៤% |

▪ការងារ:

| ប្រភេទ | ២០២១ (នាក់) | ២០២០ (នាក់) | %∆ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារធ្វើ(ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ៤ ៨២៣ | ១៧ ២០១ | -៧២,០% |
| អ្នកទទួលការងារធ្វើថ្មីតាមរយៈក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងទីភ្នាក់ងារជ្រើសរើសឯកជន | ១៤៣ ៣៧១ | ២៥៧ ៥៨៩ | -៤៤,៣% |
| អ្នកទទួលបានការងារក្នុងប្រទេស | ១៤០ ០៩០ | ២៣៤ ៧៤៤ | -៤០,៣% |
| អ្នកទទួលបានការងារក្រៅប្រទេស | ៣ ២៨១ | ២២ ៨៤៥ | -៨៥,៦% |

▪***វិនិយោគ**:គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក.*

| ប្រភេទ | ២០២១ | ២០២០ | %∆ |
|---|---|---|---|
| **អនុញ្ញាតសរុប (លានដុល្លារ)** | ៤ ៣៥៥,៤ | ៨ ២៥០,៨ | -៤៧,២% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ១៣៤,៦ | ១៤៧,១ | -៨,៥% |
| វិស័យឧស្សាហកម្ម | ២ ១៧១,៥ | ១ ៤៧០,៦ | +៤៧,៧% |
| (ក្នុងនោះក្នុងតំបន់សេដ្ឋកិច្ចពិសេស) | ៧៥៥,៦ | ២៣៦,២ | +២១៩,៩% |
| វិស័យទេសចរណ៍ | ១២៧,៨ | ៣ ៨៦០,១ | -៩៦,៧% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ១ ៩២១,៤ | ២ ៧៧៣,០ | -៣០,៧% |
| **ចំនួនគម្រោងថ្មីនិងពង្រីក (ចំនួន)** | ១៦៩ | ២៣៨ | -២៩,០% |
| **ចំនួនពលករ (ពាន់នាក់)** | ១១៣,០ | ១៥១,០ | -២៥,២% |

▪***សេវាកម្មនិងទេសចរណ៍:***

➢**ទំនិញឆ្លងកាត់កំពង់ផែ** (សរុប២កំពង់ផែ)មានចំនួន ១០ ៨៣៦,២ពាន់តោនកើនឡើង ៤,៥%ធៀបនឹងឆ្នាំ២០២០។ ក្នុងនោះ:

| ប្រភេទ | ២០២១ (ពាន់តោន) | ២០២០ (ពាន់តោន) | %∆ |
|---|---|---|---|
| កំពង់ផែភ្នំពេញ | ៣ ៨៤៥,៨ | ៣ ៩២៥,៦ | -២,០% |
| កំពង់ផែកំពង់សោម | ៦ ៩៩០,៣ | ៦ ៤៤០,៤ | +៨,៥% |

➢**ការចុះបញ្ជី និងចរាចរណ៍**

**ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍**

| ប្រភេទ | ២០២១ (ចំនួន) | ២០២០ (ចំនួន) | %∆ |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី (ពាន់គ្រឿង) | ៤៣២,៣ | ៣៧០,៦ | +១៦,៦% |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី(ពាន់គ្រឿង) | ៧៤,០ | ៨៦,០ | -១៤,០% |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍(លើក) | ២ ៦៧០ | ៣ ១៧៨ | -១៦,០% |

➢**ប្រៃសណីយ៍និងទូរគមនាគមន៍**

| ប្រភេទ | ២០២១ | ២០២០ | %∆ |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១៤១,៩ | ១៧២,២ | -១៧,៦% |
| ក្នុងនោះទទួល | ៣៣,៦ | ៣៧,១ | -៩,២% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៣៣០,៦ | ៤១៣,៨ | -២០,១% |

| | | | |
|---|---|---|---|
| ក្នុងនោះទទួល | ២៧៩,៩ | ២៧៨,៥ | ០,៥% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | — | ១២ ៥២០,១ | — |
| ក្នុងនោះហៅចូល | — | ៥ ២៧៤,៦ | — |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | — | ៣៨ ១០៣,០ | — |
| ក្នុងនោះហៅចូល | — | ៣៧ ៤៦៦,២ | — |

➢**អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍**

| *ប្រភេទ* | ២០២១ (ពាន់នាក់) | ២០២០ (ពាន់នាក់) | %Δ |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១,៣ | ៤៦,១ | -៩៧,២% |
| ភ្ញៀវទេសចរបរទេសទិញបណ្ណទស្សនាអង្គរ | ១២,៩ | ៤០០,៩ | -៩៦,៨% |
| ភ្ញៀវទេសចរចូលទស្សនា រមណីយដ្ឋានព្រះវិហារ | ៤៨,៤ | ១២២,៩ | -៦០,៦% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៨,០ | ២៤៦,៦ | -៩៦,៨% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ២៥៥,០ | ១ ៨៩៧,៤ | -៨៦,៦% |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | ៣០,៥ | ៣២៦,២ | -៩០,៦% |
| អ្នកទេសចរអន្តរជាតិមកកម្ពុជា | ១៩៦,៥ | ១ ៣០៦,១ | -៨៥,០% |
| ✓តាមផ្លូវអាកាស | ៩៩,៨ | ៧៥៦,៣ | -៨៦,៨% |
| ✓ តាមផ្លូវគោក និងទឹក | ៩៦,៧ | ៥៤៩,៩ | -៨២,៤% |

## ៥. ស្ថានភាពពាណិជ្ជកម្ម

▪យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលក្នុងឆ្នាំ២០២១ មានចំនួន ១១៣ ៦៤០,៦ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ២៨ ៤១០,១ លានដុល្លារ)កើនឡើង៤៨,១% បើធៀបនឹងឆ្នាំ២០២០ក្នុងនោះ ៖

| មានការថយចុះ | មានការកើនឡើង |
|---|---|
| ប្រេងឥន្ទនៈ -៩,២% | ស្រូវសាលី +៣៧,៩% |
| ប្រេងម៉ាស៊ូត -៧,៨% | ផ្លែឈើ និងបន្លែ +៣២៤,១% |
| ប្រេងសាំង -៨,៨% | នាំចូលរបស់ស្ថានទូតមិនធ្វើអាជីវកម្ម +១៦១,១% |
| ប្រេងខ្មៅ-២៤,១% | នាំចូលក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ +២៩,៩% |
| ដែកសំណង់ -៤២,០% | ឧស្ម័ន+១,១% |
| ស៊ីម៉ង់ត៍ -៣៣,២% | រថយន្តដឹកជញ្ជូន +២,៥% |
| រថយន្តសរុប -២,៥% | ត្រាក់ទ័រ និងគោយន្ត +៣១,២% |
| អង្ករ -៤៧,៤% | |
| ប្រេងសាំងយន្តហោះ -១៦,១% | |
| រថយន្តទេសចរណ៍ -៦,៥% | |
| ជីកសិកម្ម -៤៤,៩% | |
| ថ្នាំកសិកម្ម-៥១,៣% | |

▪**ការនាំចេញ**ឆ្នាំ២០២១មានចំនួន ៧២ ០៣៧,៤ ប៊ីលានរៀល(គិតជាដុល្លារអាមេរិក ១៨ ០០៩,៤ លានដុល្លារ) ស្មើនឹង៦៣,៤%នៃការនាំចូល មានការកើនឡើង២,១% ធៀបនឹងឆ្នាំ២០២០ក្នុងនោះ ៖

| *ទំនិញ* | %Δ ធៀបនឹង-២០២០ | *ទំនិញ* | %Δ ធៀបនឹង-២០២០ |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | +១៥,០% | ផលិតផលនេសាទ | +៣,៧% |
| វាយនភណ្ឌនិងស្បែកជើង | +១៣,២% | កៅស៊ូ | +២០,៣% |
| អង្ករ | –២,៧% | | |

## ១- វិបត្តិនយោបាយរវាង Russia ជាមួយ Ukraine

បន្ទាប់ពីការបែងចែកនៃប្រទេសប៉ូឡូញក្នុងឆ្នាំ១៧៧២ ឆ្នាំ១៧៩៣ និងឆ្នាំ១៧៩៥ ភាគខាងលិច Ukraine បានធ្លាក់នៅក្រោមការគ្រប់គ្រងរបស់អូទ្រីស ហើយទឹកដីដែលនៅសល់បានក្លាយជាផ្នែកមួយនៃចក្រភពរុស្ស៊ី។

នៅឆ្នាំ១៩២២ Ukraine និងរុស្ស៊ី គឺជាសមាជិកស្ថាបនិកពីរនៃសហភាពនៃសាធារណរដ្ឋសង្គមនិយមសូវៀត និងជាហត្ថលេខីនៃសន្ធិសញ្ញាដែលបានបញ្ចប់សហជីពនៅខែធ្នូ ឆ្នាំ១៩៩១។

ក្រោយសង្គ្រាមលោកលើកទី២ តំបន់ភាគខាងលិចនៃប្រទេស Ukraine បានបញ្ចូលជាសាធារណៈរដ្ឋសង្គមនិយមសូវៀត ហើយប្រទេសទាំងមូលបានក្លាយជាផ្នែកមួយនៃសហភាពសូវៀត។ នៅឆ្នាំ១៩៩១ បន្ទាប់ពីការរំលាយសហភាពសូវៀត Ukraine ទទួលបានឯករាជ្យ។

សម្ព័ន្ធមិត្តនៃអង្គការ NATO ដែលភ័យខ្លាចចំពោះការលុកលុយដ៏មានសក្តានុពលរបស់រុស្ស៊ី សហរដ្ឋអាមេរិកបានបង្កើនការគាំទ្រដល់ទីក្រុង Kyiv ឬ Kiev ដោយបញ្ជូនកងទ័ពបន្ថែម និងសម្ភារៈយោធាទៅកាន់ប្រទេស Ukraine យ៉ាងច្រើនសន្ធឹកសន្ធាប់ដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រឯករាជ្យរបស់ប្រទេសនេះ នៅឆ្នាំ១៩៩១។ សម្ព័ន្ធភាពនេះនិយាយថា សកម្មភាពរបស់ខ្លួនគឺឆ្លើយតបទៅនឹងការបន្តការកសាងយោធារបស់រុស្ស៊ីនៅតាមព្រំដែននៃប្រទេស Ukraine។ ដោយឡែក ទីក្រុងមូស្គូអះអាងថា សកម្មភាពរបស់ខ្លួន គឺចាំបាច់ដើម្បីធានាបាននូវផលប្រយោជន៍សន្តិសុខដ៏សំខាន់ ហើយបានស្តីបន្ទោសអង្គការ NATO ចំពោះការធ្វើឱ្យខូចសន្តិសុខក្នុងតំបន់។

ហេតុអ្វីបានជាមានជម្លោះ?

Ukraine ជាផ្នែកមួយនៃចក្រភពរុស្ស៊ីអស់ជាច្រើនសតវត្ស មុននឹងក្លាយជាសាធារណៈរដ្ឋសូវៀត ក្រោយមក Ukraine បានទទួលឯករាជ្យនៅពេលដែលសហភាពសូវៀតបានបែកបាក់នៅឆ្នាំ១៩៩១ នាំឱ្យមានការផ្លាស់ប្តូរបាត់បង់កេរ្តិ៍ដំណែលចក្រពត្តិរុស្ស៊ី ហើយប្រទេស Ukraine ក៏បានបង្កើតទំនាក់ទំនងជិតស្និទ្ធកាន់តែខ្លាំងឡើងជាមួយលោកខាងលិច។

ការសម្រេចចិត្តរបស់ប្រធានាធិបតី Ukraine ដែលគាំទ្រដោយវិមានក្រឹមឡាំង លោក Viktor Yanukovych ក្នុងការបដិសេធកិច្ចព្រមព្រៀងសមាគមជាមួយសហភាពអឺរ៉ុបក្នុងការពេញចិត្តនៃទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយទីក្រុងមូស្គូបាននាំឱ្យមានការតវ៉ាទ្រង់ទ្រាយធំនោះលោក Yanukovych ត្រូវបានដកចេញពីតំណែងជាមេដឹកនាំនៅក្នុងឆ្នាំ២០១៤។

ប្រទេសរុស្ស៊ីបានឆ្លើយតបដោយការបញ្ចូលឧបទ្វីប Crimea របស់ Ukraine និងទម្លាក់ទម្ងន់របស់ខ្លួននៅពីក្រោយការបះបោរបំបែកខ្លួន ដែលបានផ្ទុះឡើងនៅភាគខាងកើតនៃប្រទេស Ukraine។

Ukraine និងលោកខាងលិចបានចោទប្រកាន់រុស្ស៊ីថា បានបញ្ជូនកងទ័ព និងអាវុធរបស់ខ្លួនទៅគាំទ្រក្រុមឧទ្ទាម។ ទីក្រុងម៉ូស្គូ បានបដិសេធចំពោះការលើកឡើងនេះ ដោយនិយាយថា ជនជាតិរុស្ស៊ីដែលបានចូលរួមជាមួយក្រុមបំបែកខ្លួន គឺជាអ្នកស្ម័គ្រចិត្ត។

យោងតាមទីក្រុង Kyiv មនុស្សជាង ១៤០០០នាក់ បានស្លាប់នៅក្នុងការប្រយុទ្ធដែលបានបំផ្លិចបំផ្លាញ Donbas ដែលជាបេះដូងឧស្សាហកម្មភាគខាងកើតរបស់ប្រទេស Ukraine។

សម្រាប់ផ្នែករបស់ខ្លួន ទីក្រុងមូស្គូបានរិះគន់យ៉ាងខ្លាំងដល់សហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្ត NATO ដែលផ្តល់អាវុធដល់ប្រទេស Ukraine និងធ្វើសមយុទ្ធរួមគ្នា ដោយនិយាយថា ទង្វើបែបនេះលើកទឹកចិត្តដល់ Ukrainien ឱ្យព្យាយាមដណ្តើមយកតំបន់ដែលកាន់កាប់ដោយក្រុមឧទ្ទាមមកវិញ។

ជាងនេះទៅទៀត ប្រធានាធិបតីរុស្ស៊ី លោក Vladimir Putin បាននិយាយម្តងហើយម្តងទៀតថា បំណងប្រាថ្នារបស់ Ukraine ក្នុងការចូលរួមជាមួយអង្គការ NATO គឺជាបន្ទាត់ក្រហម ហើយបានសម្តែងការព្រួយបារម្ភអំពីផែនការរបស់សមាជិក NATO មួយចំនួន ក្នុងការបង្កើតមជ្ឈមណ្ឌលហ្វឹកហ្វឺនយោធានៅ Ukraine។ លោកបាននិយាយថា នេះនឹងផ្តល់ឱ្យពួកគេនូវការឈរជើងខាងយោធាក្នុងតំបន់ បើ ទោះជាគ្មាន Ukraine ចូលជាសមាជិក NATO ក៏ដោយ។

តើរុស្ស៊ីចង់បានអ្វី?

អ្វីដែលរុស្ស៊ីមិនចង់បាននោះគឺ Ukraine ចូលជាសមាជិកអង្គការ NATO ហើយបាននិយាយច្រើនក្នុងបញ្ជីទាមទារសន្តិសុខរបស់ខ្លួនដែលត្រូវបានបញ្ជូនទៅអាមេរិកកាលពីខែធ្នូឆ្នាំមុន។ការទាមទារនោះរួមបញ្ចូលទាំងការបញ្ឈប់សមយុទ្ធ NATO នៅជិតព្រំដែនរុស្ស៊ី។

ទីក្រុងមូស្គូនៅតែរង់ចាំការឆ្លើយតប ប៉ុន្តែឱសានវាទជាច្រើនត្រូវបានរិះគន់ថា មិនមែនជាការចាប់ផ្តើមដោយលោកខាងលិច។ រុស្ស៊ីក៏ចង់ឱ្យអង្គការ NATO ដកខ្លួនចេញពីអឺរ៉ុបខាងកើតផងដែរ។ នៅពេលនោះ លោក Putin បាននិយាយថា រុស្ស៊ីនឹងស្វែងរកការធានា "ដែលមិនរាប់បញ្ចូលការបន្តដំណើររបស់ NATO ទៅទិសខាងកើត និងការដាក់ពង្រាយប្រព័ន្ធសព្វាវុធដែលគំរាមកំហែងទឹកដីរុស្ស៊ី"។

លោក Putin បានផ្តល់ឱកាសឱ្យលោកខាងលិចចូលរួមក្នុងកិច្ចពិភាក្សាសំខាន់ៗលើបញ្ហានេះ ដោយបន្ថែមថា ទីក្រុងមូស្គូនឹងមិនត្រូវការការធានាដោយពាក្យសំដីប៉ុណ្ណោះទេ ប៉ុន្តែ "ការធានាផ្នែកច្បាប់" ។ រីឯការចូលរួមរបស់ Ukraine ក្នុងសម្ព័ន្ធភាពនឹងតម្រូវឱ្យមានការយល់ព្រមជាឯកច្ឆ័ន្ទពីរដ្ឋទាំង 30 ដែលបង្កើតជាស្ថាប័ន។

តើ Ukraine នឹងចូលជាសមាជិក NATO ទេ?

បច្ចុប្បន្ន Ukraine មិន មែន ជា សមាជិក NATO ទេ ប៉ុន្តែ Ukraine ចង់ ដោយចាត់ទុកខ្លួនឯងជាដៃគូនៃសម្ព័ន្ធភាព។

មុននឹងត្រូវបានគេពិចារណាចូលជាសមាជិក NATO និយាយថា Kyiv ត្រូវ លុបបំបាត់ការវាយប្រហារនានាដូចជា អំពើពុករលួយ។ល។

អគ្គលេខាធិការអង្គការ NATO លោក Jens Stoltenberg កាលពីខែធ្នូ បានច្រានចោលការទាមទាររបស់រុស្ស៊ី ដើម្បីលុបចោលការប្តេជ្ញាចិត្តឆ្នាំ២០០៨ ចំពោះ Ukraine ដែលថាថ្ងៃណាមួយប្រទេសនេះនឹងក្លាយទៅជាសមាជិក។

លោក Stoltenberg បន្តថា នៅពេលដល់ពេលពិចារណាលើបញ្ហានេះ រុស្ស៊ីនឹងមិនអាច veto ការចូលជាសមាជិករបស់ Ukraine ឡើយ។

ទោះបីជាយ៉ាងណាក៏ដោយ ក្រុមអ្នកវិភាគនិយាយថា សម្ព័ន្ធមិត្ត NATO ដែលជាប្រមុខសហរដ្ឋអាមេរិកក្នុងចំណោមពួកគេ មានការស្ទាក់ស្ទើរក្នុងការពង្រីកទីតាំងយោធារបស់ពួកគេនៅក្នុងតំបន់ និងធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនងរបស់ពួកគេជាមួយទីក្រុងម៉ូស្គូបន្ថែមទៀត។

ខណៈពេលដែលរដ្ឋមន្ត្រីការបរទេសអាមេរិក លោក Antony Blinken បានសម្តែងការគាំទ្រចំពោះសមាជិកភាពរបស់ Ukraine នៅក្នុងអង្គការ NATO តែលោកប្រធានាធិបតី Joe Biden មានភាពមិនច្បាស់លាស់ចំពោះសំណួរនេះ។

តើនឹងមានសង្គ្រាមគ្រប់បែបយ៉ាងទេ?

បស្ចិមប្រទេសកំពុងចោទរុស្ស៊ីដែលបានប្រមូលទាហាន ១០ម៉ឺននាក់នៅព្រំដែន Ukraine ថា រៀបចំខ្លួនដើម្បីឈ្លានពានប្រទេសជិតខាងដែលគាំទ្រលោកខាងលិច។

លោកBidenបានទាមទារ"ឯកភាពទាំងស្រុង"អំពីរបៀបដោះស្រាយជាមួយរុស្ស៊ីដែលមន្ទីរបញ្ចកោណបានត្រៀមទាហានអាមេរិកចំនួន ៨៥០០នាក់ រង់ចាំសម្រាប់ការដាក់ពង្រាយនៅអឺរ៉ុបខាងកើត ហើយ NATO បាននិយាយថា ខ្លួនកំពុងបញ្ជូននាវា និងយន្តហោះដើម្បីពង្រឹងការការពារក្នុងតំបន់។

អ្នកនាំពាក្យរបស់ប្រធានាធិបតី Putin លោក Dmitry Peskov បាននិយាយថា សកម្មភាពទាំងនេះ គ្រាន់តែបន្ថែមទៅក្នុងបរិយាកាសតានតឹងប៉ុណ្ណោះ។

លោក Peskov បានប្រាប់អ្នកយកព័ត៌មានថា "សហរដ្ឋអាមេរិកកំពុងបង្កើនភាពតានតឹង" ដូច្នេះ "យើងកំពុងមើលសកម្មភាពរបស់អាមេរិកទាំងនេះដោយក្តីបារម្ភយ៉ាងខ្លាំង ហើយ "រុស្ស៊ីបដិសេធថា ខ្លួនគ្មានផែនការឈ្លានពាន Ukraine ហើយ ថែមទាំងចោទលោកខាងលិចថា ធ្វើឱ្យស្ថានការណ៍កាន់តែធ្ងន់ធ្ងរ"។

រួមសេចក្តីមកវាមិនប្រាកដទេថាតើសង្គ្រាមនឹងផ្ទុះឡើងរវាងប្រទេសទាំងពីរឬយ៉ាងណា? ប៉ុន្តែអ្នកវិភាគខ្លះនិយាយថារុស្ស៊ីអាចឈានជើងចូលUkraineដើម្បីទាមទារជ័យជម្នះយ៉ាងរហ័សនិងសម្រេចបាននិងបង្កើនអំណាចចរចារបស់ខ្លួននៅក្នុងការពិភាក្សានាពេលអនាគតអំពីការពង្រីកឥទ្ធិពលរបស់អង្គការ NATO។

លោក Samir Puri អ្នកជំនាញជាន់ខ្ពស់នៅវិទ្យាស្ថានអន្តរជាតិសម្រាប់ការសិក្សាយុទ្ធសាស្ត្រ បាននិយាយ "ខ្ញុំគិតថា អ្វីដែលរុស្ស៊ី និងលោក Vladimir Putin នឹងក្លាយជាការពិត គឺការកម្ទាត់កងកម្លាំងប្រដាប់អាវុធ Ukraine នៅក្នុងវិស័យនេះ ធ្វើឱ្យមានការបរាជ័យផ្នែកយោធាដែលធ្វើឱ្យជនជាតិ Ukraine អាម៉ាស់មុខ ហើយតាមរយៈការបន្តបង្កើតការព្រួយបារម្ភថាការគាំទ្រ Ukraine មានពីសម្ព័ន្ធមិត្តនៅលោកខាងលិច។

តើមានអ្វីកើតឡើងប្រសិនបើរុស្ស៊ីឈ្លានពាន Ukraine?

ប្រទេសលោកខាងលិចបានទម្លាក់ការគាំទ្ររបស់ពួកគេនៅពីក្រោយUkraineប៉ុន្តែការឆ្លើយតបខ្លះមានភាពតឹងរ៉ឹងជាងប្រទេសដទៃទៀត។ សហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស បានផ្គត់ផ្គង់សព្វាវុធ ខណៈអាល្លឺម៉ង់គ្រោងនឹងបញ្ជូនកន្លែងព្យាបាលនៅខែក្រោយ ប៉ុន្តែនឹងមិនផ្ទេរឧបករណ៍យោធាទេ។

ទន្ទឹមនេះក៏មានការពិភាក្សាជាច្រើនអំពីទណ្ឌកម្មដែលមានគោលបំណងដាក់មកលើទីក្រុងម៉ូស្គូដែលជាសាធារណៈ សម្ព័ន្ធមិត្តរបស់អាមេរិក និងអឺរ៉ុបបានសន្យាថា នឹងវាយលុករុស្ស៊ីផ្នែកហិរញ្ញវត្ថុដែលមិនធ្លាប់មានពីមុនមក ប្រសិនបើ លោក Putin បញ្ជូនយោធារបស់គាត់ចូលទៅក្នុងប្រទេស Ukraine ។

វិមានក្រឹមឡាំងបាននិយាយកាលពីថ្ងៃទី២៧ខែមករាឆ្នាំ២០២២ថាការបដិសេធរបស់សហរដ្ឋអាមេរិកចំពោះការទាមទារសំខាន់ៗរបស់រុស្ស៊ីក្នុងការដោះស្រាយវិបត្តិលើUkraineបានបន្សល់ទុកនូវភាពសុទិដ្ឋិនិយមតិចតួច ខណៈ ដែលបន្ថែមថាការសន្ទនានៅតែអាចធ្វើទៅបាន។

ភាពតានតឹងបានកើនឡើងក្នុងប៉ុន្មានសប្តាហ៍ថ្មីៗនេះ ខណៈដែលសហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្តរបស់អង្គការ NATO បានសម្តែងការព្រួយបារម្ភថា ការកើនឡើងនៃទាហានរុស្ស៊ីប្រហែល ១០០ ០០០នាក់ នៅជិតប្រទេស Ukraine ជាសញ្ញាថា ទីក្រុងម៉ូស្គូគ្រោងនឹងឈ្លានពានអតីតអ្នកជិតខាងរបស់សូវៀត។ រុស្ស៊ីបដិសេធមិនមានការរចនាបែបនេះទេ ហើយបានដាក់ចេញនូវការទាមទារជាបន្តបន្ទាប់ ដែលខ្លួននិយាយថា នឹងធ្វើឱ្យសន្តិសុខអឺរ៉ុបប្រសើរឡើង។

ប៉ុន្តែតាមការរំពឹងទុក សហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្តលោកខាងលិច បានច្រានចោលយ៉ាងម៉ឺងម៉ាត់នូវសម្បទានណាមួយលើចំណុចសំខាន់ៗរបស់ទីក្រុងមូស្គូ កាលពីថ្ងៃទី២៦ ខែមករា ដោយបដិសេធក្នុងការហាមឃាត់Ukraineជាអចិន្ត្រៃយ៍ពីការចូលរួមក្នុងអង្គការNATOហើយនិយាយថា ការដាក់ពង្រាយកងទ័ពនិងឧបករណ៍យោធានៅអឺរ៉ុបខាងកើតនៃសម្ព័ន្ធមិត្ត គឺមិនអាចចរចាបាន។

រដ្ឋមន្ត្រីការបរទេសអាមេរិកលោកAntony Blinkenបាននិយាយថា"នឹងមិនមានការផ្លាស់ប្តូរទេ" ដោយបានព្រមានម្តងទៀតថា ការលុកលុយរបស់រុស្ស៊ី ចូលទៅក្នុង Ukraine នឹងត្រូវជួបជាមួយនឹងផលវិបាកដ៏ធំនិងការចំណាយសេដ្ឋកិច្ចធ្ងន់ធ្ងរ។៕

ដោយ នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត

# ២- សម្តេចតេជោ ហ៊ុន សែន ទៅកាន់មីយ៉ាន់ម៉ា ដើម្បីលើកទង់អាស៊ានឱ្យគ្រប់១០ឡើងវិញ

ផែនដីកម្ពុជាឆ្នាំ២០២២នេះ គឺជាប្រធានអាស៊ាន បន្ទាប់ពីទទួលតំណាមរតកនៃការបែកបាក់ពីប្រទេសប្រ៊ុយណេជាម្ចាស់ផ្ទះកន្លងមក ហើយដោយឈរលើកិច្ចព្រមព្រៀងជាឯកច្ឆន្ទប្រាំចំណុច(5PC) របស់អាស៊ាន និងយោងតាមលទ្ធផលនៃដំណើរទស្សនកិច្ចជាផ្លូវការរបស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃកម្ពុជាទៅកាន់រដ្ឋធានីណៃពិដោរ នៃប្រទេសមីយ៉ាន់ម៉ា ដើម្បីជួបពិភាក្សាជាមួយមេដឹកនាំយោធាមីយ៉ាន់ម៉ា លោក **មីន អ៊ុងលាំង**( Min Aung Hlaing )កាលពីថ្ងៃទី៧-៨ ខែមករា ឆ្នាំ២០២២ កន្លងមកនេះ ដោយមេដឹកនាំយោធាមីយ៉ាន់យ៉ាបានប្រកាសជាឯកតោភាគីជាឱឡារិកដល់សាធារណៈជាតិនិងអន្តរជាតិថា នឹងពន្យារពេលពីបទឈប់បាញ់រហូតដល់ចុងឆ្នាំ២០២២ ធានាដល់ការចែកជំនួយមនុស្សធម៌ ដល់ប្រជាជនមីយ៉ាន់ម៉ា និងបើកផ្លូវឱ្យប្រេសិតពិសេសរបស់ប្រធានអាស៊ាន ទៅបំពេញទស្សនកិច្ចនៅប្រទេសមីយ៉ាន់ម៉ា ដើម្បីជួបចរចាជាមួយភាគីពាក់ព័ន្ធនោះគឺពិតជាពន្លឺមួយដ៏ត្រចះត្រចង់ក្នុងការទម្លុះទម្លាយពីភាពបែកបាក់អាស៊ាន ដើម្បីលើកទង់អាស៊ានឱ្យគ្រប់១០ឡើងវិញ។

ស្ថិតក្នុងន័យថាចំពោះដំណើរទស្សនកិច្ចរបស់សម្តេចតេជោ **ហ៊ុន សែន** ជាការមិនចង់ឱ្យអាស៊ាននៅត្រាំត្រៃនឹងការបែកបាក់ ដើម្បីនាំអាស៊ានមករួមរស់ជាសហគមន៍តែមួយ វាសនាតែមួយ នឹងទប់ស្កាត់កុំឱ្យមីយ៉ាន់ម៉ា ធ្លាក់ចូលទៅក្នុងសង្គ្រាមស៊ីវិល ដូចដែលកម្ពុជាធ្លាប់ជួបប្រទះកន្លងមក សំដៅឈានទៅសម្រេចបាននូវសន្តិភាពយូរអង្វែង និងការអភិវឌ្ឍជាតិជូនប្រជាជាតិមីយ៉ាន់ម៉ាផ្ទាល់ក៏ដូចជាសន្តិភាពក្នុងតំបន់ និងពិភពលោក។

ព្រោះបេះដូងសម្តេចតេជោ គឺជា "បេះដូងសន្តិភាព" ដោយកម្ពុជាធ្លាប់ហែលឆ្លងនូវការបែកបាក់ជាតិនឹងសង្គ្រាមរ៉ាំរ៉ៃផ្ទៃក្នុងអស់រយៈពេលប្រមាណ៥០០ឆ្នាំពិសេសពីឆ្នាំ១៩៧០ដល់១៩៧៩។សព្វថ្ងៃកម្ពុជាមានសន្តិភាពយ៉ាងពេញលេញកំពុងរះឡើងនៅលើទឹកដីដែលធ្លាប់កំសត់មួយនេះដ៏ស្រស់បបរទៅកាន់ពិភពលោកយ៉ាងស្រស់បំព្រង។

ហេតុនេះបើពោលពីការបែកបាក់ជាតិ សង្គ្រាមរ៉ាំរ៉ៃ និងព្រឹត្តិការណ៍រដ្ឋប្រហារនៅប្រទេសមីយ៉ាន់ម៉ា ក៏ដូច្នោះដែរ គឺនរណាក៏ដឹងដែរថា ចាប់តាំងពីអំឡុងពេលដែលចក្រភពអង់គ្លេសចូលកាន់កាប់ រហូតប្រគល់ឯករាជ្យនាឆ្នាំ១៩៤៨មក ប្រទេសមួយនេះត្រូវស្ថិតនៅក្នុងបរិបទគ្រប់គ្រងដោយរបបផ្តាច់ការយោធានិយមរហូតមកដល់បច្ចុប្បន្ន ពិសេសក្រោមការដឹកនាំរបស់លោកប្រធានាធិបតី និងមេទ័ពផ្តាច់ការ លោក **នេវិន** ពីឆ្នាំ១៩៥៨ដល់១៩៧៤ អ្វីដែលពិភពលោកនៅតែចងចាំនោះ គឺប្រទេសមួយនេះបែរជាត្រូវបានល្បីល្បាញដោយមានឥស្សរជនជាន់ខ្ពស់មួយរូប គឺលោក **អ៊ូ ថាន់** (U Thant) បានត្រូវតែងតាំងជាអគ្គលេខាធិការអង្គការសហប្រជាជាតិចំនួន២អាណត្តិ ចាប់ពីឆ្នាំ១៩៦១-១៩៦៦ និងពីឆ្នាំ១៩៦៦-១៩៧១ ទៅវិញ ។ សំនួរសួរថា តើពិភពលោកមានការរអ៊ូរទាំចំពោះមីយ៉ាន់ម៉ា ថាដឹកនាំក្រោមរបបផ្តាច់ការយោធាឬទេ? ចម្លើយគឺអត់ទេ!ពិភពលោកនៅតែរអូករអឺនជាមួយប្រទេសមីយ៉ាន់ម៉ាក្រោមរបបផ្តាច់ការយោធា!យ៉ាងអស្ចារ្យបំផុត។

ចំពោះភូមិសាស្ត្រនយោបាយអាស៊ាន បានប្រែប្រួលខុសពីទស្សវត្សឆ្នាំ១៩៧០។ខុសត្រង់ថា អាស៊ានពេលនេះ បានក្លាយជាតំបន់ដែលមានសារៈសំខាន់យ៉ាងខ្លាំងខាងនយោបាយ យោធានិងសេដ្ឋកិច្ច ក្នុងការប្រគួតប្រជែងឥទ្ធិពលគ្នាយ៉ាងក្តៅគគុករវាងមហាអំណាចអាមេរិកនិងចិន។ ទន្ទឹមនឹងនេះ ដោយសារតែមាននិន្នាការនៃសមាជិកអាស៊ាននីមួយៗ វាក៏អាចជាប្រកតពដែលនាំឱ្យផ្ទៃក្នុងអាស៊ានខ្លួនឯងត្រូវប្រឈមផងដែរ។ ដូចនេះចំពោះដំណោះស្រាយអាចជាការប្រើពេល ដូចប្រសាសន៍សម្តេចតេជោ កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ នៅខេត្តព្រះសីហនុ បានគូសបញ្ជាក់យ៉ាងច្បាស់ថា " កិច្ចការរបស់អាស៊ានឆ្នាំ២០២២ បញ្ហាមីយ៉ាន់ម៉ានាពេលនេះ មិនមែនដោះស្រាយបញ្ចប់ត្រឹមរយៈពេលខ្លី ឬត្រឹមដំណាក់កាលកម្ពុជាធ្វើជាប្រធានអាស៊ាននោះទេ " អាចបន្តធ្លាក់ទៅដល់ដៃរបស់ប្រទេសឥណ្ឌូនេស៊ីឆ្នាំ២០២៣ អនាគតខាងមុខ។

ដូច្នេះចំពោះដំណើរទស្សនកិច្ចរបស់សម្តេចតេជោទៅកាន់មីយ៉ាន់ម៉ាគឺជាពន្លឺមួយដើម្បីឈានទៅដល់ឯកភាពអាស៊ានសាមគ្គីភាពនិងមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងដើម្បីលើកទង់អាស៊ានឱ្យគ្រប់ទាំង១០ឡើងវិញ ដូចដែលរដ្ឋមន្ត្រីការបរទេសជប៉ុនលោក **យ៉ូស៊ីម៉ាស្សា ហាយ៉ាស៊ី** ( Yoshimasa Hayashi) បានថ្លែងសាទរដ៏ប្រពៃថ្លៃថ្លាថា " ដំណើរទស្សនកិច្ចរបស់សម្តេចតេ គឺទទួលលទ្ធផលវិជ្ជមានដ៏ប្រសើរ " ស្ថិតក្រោមរបបយោធាមីយ៉ាន់ម៉ាទាំងនេះ៕

ដោយ វ័ត្ន សណ្តាប់

# ពីវត្តភ្នំដូនពេញទៅជាក្រុងភ្នំពេញ រាជធានីនៃព្រះរាជាណាចក្រកម្ពុជា

## ១- ប្រវត្តិវត្តភ្នំដូនពេញ

មានរឿងតំណាលថា កាលកន្លងទៅ ក្នុងគ.ស.១៣៧២ (ឯកសារខ្លះថាគ.ស.១៣៧៨) មានដូនម្នាក់ឈ្មោះ ពេញ ជាអ្នកមានទ្រព្យសម្បត្តិបរិបូរ និងមានទីលំនៅក្បែរច្រាំងទន្លេ៤មុខ (ទន្លេចតុមុខ)។ ផ្ទះគាត់សង់នៅខាងកើតទួលខ្ពស់មួយ។

សម័យថ្ងៃមួយ មានភ្លៀងខ្លាំងព្រមពេលទឹកទន្លេជន់លិចរហាចរហឹម ជាហេតុនាំឱ្យសំណាក់ដើមគគីរមួយធំអណ្តែតមកតាមទន្លេមេគង្គលើវិលវល់ទៅមកក្បែរច្រាំងកំពង់ទឹកដូនពេញដោយសារកម្លាំងទឹកហូរសងចុះឡើង។ ពេលដូនពេញចុះទៅកំពង់ទឹកដូចសព្វដង ស្រាប់តែឃើញសំណាក់ដើមគគីរ គាត់ក៏ប្រញាប់ទៅហៅអ្នកជិតខាងឱ្យមកជួយទាញយកដើមគគីរដែលអណ្តែតនោះមកច្រាំង។ ក្នុងប្រហោងដើមគគីរ មានព្រះពុទ្ធរូប៤អង្គតូចៗធ្វើអំពីសំរឹទ្ធិនិងទេវរូប១អង្គធ្វើអំពីថ្ម។ ទេវរូបនោះទ្រង់ឈរ ព្រះហស្តម្ខាងទ្រង់ដំបងម្ខាងទៀតទ្រង់ស័ង្ខ និងមានព្រះកេសាបួង។

ដូនពេញនិងអ្នកជិតខាងដែលបានជួយកិច្ចការនេះ មានសេចក្តីត្រេកអរណាស់ដោយរើសបានវត្ថុជាទីគោរព ក៏នាំគ្នាដង្ហែព្រះបដិមាទាំងនោះមកផ្ទះដូនពេញ ហើយគាត់ក៏ចាត់ឱ្យគេសង់ខ្ទមតូច ដើម្បីតម្កល់ជាបណ្តោះអាសន្ន។

ពេលក្រោយមក ដូនពេញក៏អំពាវនាវឱ្យអ្នកភូមិជួយលើកដី ពូនទួលខ្ពស់ដែលនៅខាងលិចផ្ទះរបស់គាត់ ឱ្យមានទំហំធំជាងមុនបានជាកូនភ្នំមួយ។ បន្ទាប់មក គាត់ក៏ចាត់ឱ្យគេអារដើមគគីរនោះធ្វើជាសសរព្រះវិហារដែលគាត់បម្រុងសង់លើកូនភ្នំនោះ។

ក្នុងគ.ស.១៣៧២ដដែល ព្រះវិហារមួយខ្នងប្រក់ស្បូវភ្លាំង ត្រូវបានកសាងនៅលើកំពូលកូនភ្នំ ហើយដូនពេញក៏ដង្ហែព្រះពុទ្ធរូបសំរឹទ្ធិទាំង៤អង្គទៅតម្កល់នៅទីនោះ។ ចំណែកឯទេវរូបថ្ម គាត់ក៏ដង្ហែទៅតម្កល់ដោយឡែកនៅអាសនៈមួយស្ថិតនៅជើងភ្នំផ្នែកខាងកើត ដោយគាត់យល់ថា ដើមគគីរនោះរសាត់អណ្តែតមកពីស្រុកលាវតាមទឹកទន្លេមេគង្គជន់លិច ហើយរូបក៏មានទម្រង់ដូចបដិមាលាវផង គាត់ក៏សន្មតហៅរូបនោះថា **អ្នកតាព្រះចៅ** ហើយនាមនោះ ក៏ត្រូវបានខ្មែរយើងប្រើរហូតដល់សព្វថ្ងៃ។

ក្រោយសង់ព្រះវិហាររួច គាត់ក៏និមន្តព្រះសង្ឃមកគង់នៅជើងភ្នំនោះផ្នែកខាងលិច ទើបមានឈ្មោះថា **វត្តភ្នំដូនពេញ** ដែលផ្សំដោយពាក្យសម្គាល់វ័យនិងឈ្មោះគឺ **ដូនពេញ** និងពាក្យសម្គាល់ភ្នំនិងវត្តគឺ **វត្តភ្នំ** (វត្តនៅលើភ្នំ) ហើយចំណោរក្រោយមក ប្រជាជនហៅខ្លីថា **ភ្នំពេញ** រៀងរហូត។



ពិធីដង្ហែបដិមាព្រះពុទ្ធរូបនិងទេវរូបទៅតម្កល់
ប្រភព : សៀវភៅទិវានុលេខន៍សាលារាជធានីភ្នំពេញ ឆ្នាំ២០១១




ប្លង់កសាងរាជធានីរបស់ព្រះបាទពញាយ៉ាត គ.ស.១៤៣៤
ប្រភព : អង្គការស៊ីប៉ា-ជនជាតិខ្មែរ ភាគ២ ឆ្នាំ២០០៤

## ២- ព្រះបាទពញាយ៉ាត គ.ស.១៤២១-១៤៦៣ : ស្ថាបនិករាជធានីភ្នំពេញ

ចូលមកដល់ដំណាក់កាលទី២គឺសម័យព្រះបាទពញាយ៉ាតមកតាំងរាជធានីនៅចតុមុខ។ដំណាក់កាលនេះបន្តប្រវត្តិសាស្ត្រខ្មែរពីរាជធានីអង្គរ។ ក្នុងសង្គ្រាមខ្មែរ-សៀមចុងក្រោយ ក្នុងរាជ្យព្រះបរមសុខា(គ.ស. ១៤១៧-១៤២០)ដែលសៀមកាន់កាប់អង្គរបាន ព្រះពញាយ៉ាតបាននាំពលសេនាដកថយបណ្ដោះអាសន្នមកទួលបាសាន ស្រុកសន្ធរ។ គឺពីនេះហើយដែលព្រះអង្គរៀបចំកម្លាំងទ័ពជាថ្មី ហើយនៅគ.ស.១៤២១ ព្រះអង្គលើកទ័ពនិងប្រើល្បិចបង្កប់ផ្ទៃក្នុងវាយយករាជធានីអង្គរបានមកវិញ។អស់រយៈពេល៧ឆ្នាំដែលព្រះអង្គសោយរាជ្យនៅរាជធានីអង្គរ ព្រះអង្គឈ្វេងយល់លើហេតុផល៣យ៉ាង ដើម្បីប្ដូររាជធានីពីអង្គរមកទួលបាសាន៖

១- សៀមតាំងខ្លួនជាសត្រូវនឹងខ្មែររហូតមក ដូច្នេះទៅថ្ងៃខាងមុខ យើងនឹងមានចម្បាំងធំទៀតដែលសៀមបង្កឡើង។

២- អាណាប្រជានុរាស្ត្រមួយចំនួនត្រូវសៀមកៀរទៅ ជាហេតុនាំឱ្យយើងសល់ប្រជានុរាស្ត្រតិចពុំធួនល្មមនឹងទឹកដីដ៏ធំទូលាយ។

៣- ការតាំងរាជធានីឆ្ងាយពីអង្គរ នាំឱ្យយើងមានពេលវេលាគ្រប់គ្រាន់ទៅច្បាំងតាមខេត្ត និងតាមដំណាក់ៗតទល់ទ័ពសៀមដែលលើកមក ហើយទីតាំងថ្មីមានលក្ខណៈយុទ្ធសាស្ត្រល្អផង ព្រោះមានទន្លេធំតូចជារបាំងមុខក្រោយ។

ការតាំងរាជធានីរបស់ព្រះបាទពញាយ៉ាតនៅខេត្តបាសានមានរយៈពេលតែជាង១ឆ្នាំប៉ុណ្ណោះ(ឯកសារខ្លះថា៩ឆ្នាំ)ព្រោះភូមិសាស្ត្រនោះជាតំបន់ទឹកជន់លិចនៅរដូវទឹកឡើងដោយសារទឹកទន្លេមេគង្គ(ទន្លេធំ)និងទឹកតំបន់ទំនាបខាងក្រោយ។

ជម្រើសលើកទី២ជាទីតាំងថ្មីសម្រាប់កសាងរាជធានី គឺចតុមុខ។ ព្រះអង្គទ្រង់បន្តគង់នៅរាជធានីទួលបាសាន រហូតដល់រាជធានីថ្មីនេះកសាងរួចរាល់នៅគ.ស.១៤៣៤ ទើបព្រះអង្គយាងមកគង់នៅត្រង់ភូមិឫស្សីកែវ គឺផ្នែកខាងជើងផ្សារចាស់នៃរាជធានីយើងសព្វថ្ងៃ។

ក្នុងរយៈពេលប្រមាណ៣០ឆ្នាំនៃរាជ្យព្រះបាទពញាយ៉ាត ពីគ.ស.១៤៣៤ ដល់ គ.ស.១៤៦៣ ដែលព្រះអង្គសោយទិវង្គត គឺជាសម័យដែលតំបន់ទំនាបទន្លេមេគង្គនៃប្រទេសកម្ពុជា ត្រូវបានរៀបចំកែលម្អជាលើកដំបូងនៅខាងលិចជាប់ទន្លេចតុមុខ ដើម្បីរៀបចំជារាជធានីថ្មីសម្រាប់គ្រប់គ្រងប្រទេសទាំងមូល។

អ្វីៗត្រូវរៀបចំដំបូងទាំងអស់ទាំងហេដ្ឋារចនាសម្ព័ន្ធរាជធានីនិងទីតាំងយុទ្ធសាស្ត្រទាំងសំណង់ផ្សេងៗៈ

១- ការចាក់ដីបំពេញទីតាំងព្រះរាជវាំងឱ្យផុតពីជំនន់ទន្លេមេគង្គ។ អ្នកឧកញ៉ាតេជោ ស្រី ចៅហ្វាយស្រុក ខេត្តសំពេងទង(ក្នុងខេត្តកំពង់ស្ពឺសព្វថ្ងៃ)ទទួលបន្ទុកការងារកេណ្ឌរាស្ត្រជីកនិងជញ្ជូនដីទៅចាក់បំពេញកន្លែងទំនាបៗ និងលើកឱ្យខ្ពស់ទីកន្លែងផ្សេងៗ ក្នុងទីបរិវេណព្រះរាជវាំងរហូតដល់ជើងវត្តភ្នំ។ កន្លែងដែលអ្នកឧកញ៉ាតេជោឱ្យរាស្ត្រជីកយកអាចម៍ដីទៅចាក់បំពេញនោះ មានវិសាលភាពធំនិងជ្រៅ ដែលក្រោយមកបានក្លាយទៅជាបឹង អ្នកស្រុកហៅថា **បឹងតេជោ** រៀងមក(កន្លែងផ្សារធំថ្មីនិងទីជុំវិញសព្វថ្ងៃ)។

២- ជាមួយនេះ ព្រែកមួយប្រវែងប្រមាណ២គ.ម. ត្រូវបានជីកដើម្បីបញ្ចូលទឹកទន្លេមកក្នុងរាជធានី និងភ្ជាប់ទន្លេសាបទៅបឹងពោងពាយដ៏ធំល្វឹងល្វើយដែលនៅខាងក្រោយនិងខាងជើងរាជធានី(ចំណែកបឹងនេះ១ផ្នែក គឺបឹងកក់មុនពេលលើកទំនប់ផ្លូវ៥៩៨និង២៧៣កាត់ផ្តាច់)។ ឧកញ៉ាផ្លុង ចៅហ្វាយស្រុកខេត្តបាទីជាអ្នកទទួលបន្ទុកកេណ្ឌរាស្ត្រជីក ទើបមានឈ្មោះថា **ព្រែកពាមផ្លុង** នៅសម័យនោះ(ដល់សម័យអាណាព្យាបាលបារាំង ស្ពាននាគត្រូវបានសង់ឆ្លងព្រែកនេះ)។ក្រៅពីនេះ ក៏មានជីកព្រែកតាកែវ(ខាងត្បូងរាជធានី) ព្រែកពោងពាយ(ខាងជើង) និងមានអូរគ(អូរធម្មជាតិនៅត្រង់ផ្លូវមុខវិទ្យាល័យបាក់ទូកសព្វថ្ងៃ) ភ្ជាប់ព្រែកពោងពាយ និងព្រែកតាកែវ បង្កើតបានជាបណ្តាញផ្លូវទឹកគ្រប់គ្រាន់ សម្រាប់ប្រើប្រាស់និងការពាររាជធានី និងលើកដីតាំងជាសើន ជាបន្ទាយការពារ មានជីកជាអូរ ជាគូអមប៉មកំផែង លើកទំនប់ការពារជំនន់ទន្លេនៅរដូវទឹកឡើង...។

៣- ការកសាងវត្តចំនួន៦ គឺ១-វត្តកោះ(ទិសខាងកើតឆៀងអាគ្នេយ៍ភ្នំដូនពេញ)២-វត្តលង្កា(ទិសខាងកើតឆៀងឦសានភ្នំដូនពេញ) ៣-វត្តព្រះពុទ្ធឃោសា(នៅទិសខាងត្បូងព្រែកចិនដំដែក ប៉ែកខាងជើងភ្នំដូនពេញ) ៤-វត្តពាមផ្លុង(ទិសអាគ្នេយ៍ភ្នំដូនពេញ ជិតមាត់ព្រែកពាមផ្លុង) ៥-វត្តឧណ្ណាលោម (ទិសខាងត្បូងភ្នំដូនពេញ ប៉ែកខាងកើតបឹងតេជោ) និង៦-វត្តខ្ពបតាយ៉ង(ទិសខាងត្បូងបំផុតនៃរាជធានីថ្មី នៅជាប់ព្រែកតាកែវ)។

ព្រមពេលរៀបចំវត្តទាំងនេះ មានការកសាងព្រះវិហារ ចេតិយ កុដិ...អំពីឥដ្ឋនិងបូកបាយអ។ វត្តភ្នំដូនពេញក៏ព្រះបាទពញាយ៉ាតដាក់ព្រះរាជបញ្ជាឱ្យរៀបចំឡើងវិញដែរ។ ភ្នំត្រូវបានគេចាក់ដីពង្រីកឱ្យធំនិងខ្ពស់ជាងមុន និងកសាងព្រះវិហារថ្មីនៅទីតាំងចាស់ ដើម្បីជំនួសព្រះវិហារចាស់ដែលទ្រុឌទ្រោមព្រោះសង់យូរហើយនិងសាងចេតិយធំៗនៅក្រោយព្រះវិហារ...ព្រមទាំងរៀបចំតម្កល់ព្រះពុទ្ធរូបនិងបដិមាជាច្រើនដែលមានស្រាប់និងយកពីរាជធានីអង្គរ។ ក្នុងកំផែងក្រុងថ្មីនេះ ពួកមន្ត្រីនិងអ្នកស្រុកសង់ផ្ទះសម្បែងតាមសេចក្តីត្រូវការ។

រាជធានីថ្មីបែរទៅទិសបូព៌ ហើយមានផ្លូវក្រាលថ្មខ្វាត់ខ្វែង មានប្រាសាទ ព្រះរាជមន្ទីរ ព្រមទាំងដំណាក់ធំតូចសម្រាប់ស្រីស្នំស្រីង្គារ។ ពេលរៀបចំស្រេចការហើយ ព្រះបាទពញាយ៉ាតឡើងគង់ព្រះនិវេសន៍ថ្មី ហើយ

តាំងនាមទន្លេ៤មុខ(ឯកសារខ្លះហៅ ទន្លេច្រាបឈាម ) ហៅថា **ទន្លេចតុមុខ** នាមព្រះនគរថា **ក្រុងចតុមុខ សកលកម្ពុជាធិបតី ជាខត្តិយាមហានគរ** (ឯកសារខ្លះហៅក្រុងចតុមុខមង្គល)។ ដោយឡែក **វត្តភ្នំដូនពេញ** ត្រូវបានព្រះអង្គបញ្ញត្តឱ្យហៅ **វត្តព្រះចេតិយបព៌ត** តែចំណេរក្រោយមក ប្រជាជនហៅខ្លីត្រឹម **វត្តភ្នំពេញ**ឬ**វត្តភ្នំ** និង**ភ្នំដូនពេញ**រៀងរហូតមក។

ព្រះបាទពញាយ៉ាតគង់នៅរាជធានីថ្មី៣០ឆ្នាំ។ ព្រះអង្គមានបុត្រា៣អង្គគឺព្រះនរាយណ៍រាជា ព្រះស្រីរាជា និងព្រះធម្មរាជា។ ព្រះអង្គសុគតដោយជរារោគនៅព្រះជន្ម៧៨ព្រះវស្សា។

ព្រះនរាយណ៍រាជា បុត្រច្បងព្រះបាទពញាយ៉ាតសោយរាជ្យបន្តពីព្រះបិតា នៅរាជធានីចតុមុខ។ ព្រះអង្គបានរៀបចំកែលម្អវត្តព្រះចេតិយបព៌តម្តងទៀត និងបានកសាងចេតិយធំមួយនៅចង្កេះភ្នំ ដើម្បីបញ្ចុះព្រះសារីរិកធាតុព្រះបិតាព្រះអង្គ។ ព្រះអង្គសោយរាជ្យបាន៦ឆ្នាំ ក្នុងព្រះជន្ម៣៩ព្រះវស្សា ទ្រង់ប្រឈួនជាទម្ងន់ហើយសុគត។ព្រះស្រីរាជាជាព្រះអនុជឡើងសោយរាជ្យបន្តនៅរាជធានីចតុមុខ(មុននេះព្រះអង្គនៅខាងលិចអូរ-គ ហៅ ទួលព្រះស្រី)។ ក្នុងរាជ្យព្រះអង្គ មានច្បាំងដណ្តើមរាជ្យសម្បត្តិ បង្កើតឡើងដោយសារព្រះស្រីសុរិយោទ័យ(បុត្រព្រះនរាយណ៍រាជា) ដោយហេតុផលថា ព្រះអង្គត្រូវសោយរាជ្យបន្តពីព្រះបិតា មិនមែនព្រះស្រីរាជាជាប្អូនរបស់ព្រះបិតាទេ។ ក្នុងសម័យចម្បាំងនោះ ប្រទេសត្រូវចែកជា៣គឺ ព្រះស្រីរាជា ចេញពីចតុមុខ ទៅតាំងរាជធានីនៅខេត្តបារាយណ៍(ក្នុងខេត្តកំពង់ធំសព្វថ្ងៃ) ខណៈដែលព្រះស្រីសុរិយោទ័យ តាំងនៅទួលបាសាន(ក្នុងខេត្តកំពង់ចាមសម័យមុន)ចំណែកព្រះធម្មរាជាបន្តគង់សោយរាជ្យនៅចតុមុខរហូតដល់សោយទិវង្គតនៅគ.ស.១៥០៤។ ព្រះធម្មរាជាមានបុត្រ២ព្រះអង្គ គឺព្រះសុគន្ធបទនិងព្រះអង្គចន្ទ។



ចេតិយកសាងអំពីឥដ្ឋនិងបាយអនៅក្រោយព្រះវិហារ(ប្រក់ស្បូវភ្លាំង)
បន្សល់ទុកពីសម័យព្រះបាទពញាយ៉ាត (រូបថតឆ្នាំ១៨៨៥)
នៅផ្នែកខាងលើ ពួកអាណាព្យាបាលបាំងធ្វើរានមានបង្កាន់ដៃជុំវិញ
ដើម្បីឱ្យអ្នកយាមអាចមើលទៅទីឆ្ងាយបាន
ប្រភព : មីសែល អ៊ីហ្គូ-ភ្នំពេញពីម្សិលមិញដល់ថ្ងៃនេះ ឆ្នាំ១៩៩៣



វត្តភ្នំបច្ចុប្បន្ន : ព្រះវិហារថ្មីនិងកំពូលចេតិយព្រះរាជវង្សព្រះចៅពញាយ៉ាតនៅខាងក្រោយ(មើលពីខាងមុខ ទិសខាងកើត)
ប្រភព : បណ្ណប្រៃសណីយ៍ ឆ្នាំ១៩៩៣

ជាសរុបសេចក្តី ចតុមុខដែលរៀបចំដំបូងទៅជារាជធានី ដោយព្រះបាទពញាយ៉ាតនៅគ.ស.១៤៣៤ មានអាយុកាលបានតែចំនួន៧៤ឆ្នាំ គឺត្រូវបានបញ្ចប់នៅគ.ស.១៥០៨ ព្រោះថាចាប់ពីពេលនោះទៅ រាជធានីត្រូវបានប្តូរទៅតាំងនៅទួលបាសានវិញដោយព្រះសុគន្ធបទ។ក្នុងរយៈពេល៧៤ឆ្នាំនេះ ព្រះរាជាសំខាន់ៗមានព្រះបាទពញាយ៉ាតសោយរាជ្យ៣០ឆ្នាំ ព្រះធម្មរាជាសោយរាជ្យ២៧ឆ្នាំនិងព្រះសុគន្ធបទជាព្រះរាជាចុងក្រោយសោយរាជ្យ៥ឆ្នាំ(គ.ស.១៥០៤-១៥០៨)។

## ៣- រាជធានីផ្សេងៗទៀត ចន្លោះរាជធានីភ្នំពេញលើកទី១និងលើកទី២

ការសរសេរផ្នែកនេះបញ្ចូលក្នុងប្រវត្តិរាជធានីភ្នំពេញគឺដើម្បីបំពេញប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាយើងដោយផ្អែកលើហេតុផល២យ៉ាង៖

១-យើងអាចសរសេរប្រវត្តិរាជធានីភ្នំពេញដោយផ្អែកតែលើការតាំងរាជធានីដោយព្រះបាទពញាយ៉ាតបាន ប្រសិនបើរាជធានីយើងវិវត្តពីនោះមកដល់សព្វថ្ងៃ តែតាមការពិត ប្រវត្តិសាស្ត្រកម្ពុជានិងប្រវត្តិភ្នំពេញមិនដូច្នោះទេ។

២- ទោះជាមានការបោះបង់រាជធានីចតុមុខដោយព្រះបាទសុគន្ធបទនៅគ.ស.១៥០៨ត្រឡប់ទៅរាជធានីទួលបាសានក៏ដោយ ក៏ប្រទេសយើងនៅវត្តមានរហូត គឺមិនត្រូវបានបាត់បង់ទឹកដីទៅក្នុងប្រទេសណាមួយទេ។ ប៉ុន្តែមានព្រឹត្តិការណ៍ប្រវត្តិសាស្ត្រធំៗជាច្រើនបានកើតឡើង ក្រោយពេលបោះបង់ដោយព្រះបាទសុគន្ធបទ ជាមួយការតាំងរាជធានីច្រើនកន្លែងដោយព្រះរាជាខ្មែរ ក្នុងនោះមានរាជធានីសំខាន់ៗបីមុនដល់ការតាំងរាជធានីភ្នំពេញលើកទី២នៅគ.ស.១៨៦៧ដោយព្រះបាទនរោត្តម៖

- រាជធានីស្រឡប់ពិជ័យព្រៃនគរ(គ.ស.១៥១២-១៥២៥)កសាងដោយព្រះស្រីជេដ្ឋាធិរាជ(ស្តេចកន) ក្រោយធ្វើចម្បាំងឈ្នះព្រះបាទសុគន្ធបទ។

- រាជធានីលង្វែក(គ.ស.១៥២៨-១៥៩៤) កសាងដោយព្រះចន្ទរាជា ក្រោយធ្វើចម្បាំងឈ្នះព្រះស្រីជេដ្ឋាធិរាជ។

- រាជធានីឧត្តុង្គ(គ.ស.១៦២០-១៨៦៧)កសាងដោយព្រះជ័យជេដ្ឋាទី២ ដោយប្តូរពីល្វាឯម (ស្រុកល្វាឯម ខេត្តកណ្តាលសព្វថ្ងៃ)។

រាជធានីឧត្តុង្គមានរយៈពេលប្រមាណ២៤០ឆ្នាំ ជាមួយនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រអាក្រក់ៗជាច្រើនមានការបាត់បង់ទឹកដីខេត្តបាត់ដំបង សៀមរាប ស៊ីសុផុន ពីគ.ស.១៧៩៥ដល់១៩០៧ ដោយសារអំពើក្បត់របស់ចៅហ្វាបែន ការស្ថិតក្រោមឥទ្ធិពលសៀមនិងយួន និងការធ្លាក់ក្រោមការគ្រប់គ្រងរបស់យួនក្នុងរាជ្យព្រះក្សត្រីអង្គម៉ី គ.ស.១៨៣៤-១៨៤០ នៅរាជធានីកោះស្លាកែត(ខាងកើតទីប្រជុំជនគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាលសព្វថ្ងៃ)។

ទីតាំងរាជធានីទាំងអស់នេះ បានបង្ហាញនូវវត្តមានប្រទេសកម្ពុជាយើងនៅតំបន់អាស៊ីអាគ្នេយ៍ និងការតស៊ូរបស់បុព្វបុរសយើង រហូតដល់មានឱកាសជាថ្មីនិងតាំងរាជធានីនៅភ្នំពេញលើកទី២ បើទោះជាមានការលំបាកវេទនាធ្ងន់ធ្ងរ ស្ទើរតែរលាយបាត់ប្រទេសនៅពេលខ្លះក៏ដោយ ហើយក្នុងដំណាក់កាលនេះ យើងត្រូវនិយាយដល់អន្តរាគមន៍របស់ប្រទេសបារាំងដែលឈានទៅចុះសន្ធិសញ្ញាអាណាព្យាបាល ថ្ងៃ១១ ខែសីហា ឆ្នាំ១៨៦៣ រវាងព្រះមហាក្សត្រព្រះបាទនរោត្តមនិងលោក ឡា គ្រង់ឌីយែ តំណាងព្រះចៅអធិរាជបារាំង ដូចសេចក្តីក្នុងមាត្រា១ចែងថា «ព្រះចៅអធិរាជនៃជនជាតិបារាំងយល់ព្រមផ្តល់នូវការការពាររបស់ខ្លួនដល់ព្រះមហាក្សត្រនៃកម្ពុជា» (ត្រាំងឆាត ប៊ុត-កម្ពុជាក្រោម អំណាចគ្មានខ្មែរក្រោម ឆ្នាំ២០០៥ ទំ.៣១១)។

ចន្លោះគ.ស.១៥០៨ដល់១៨៦៧ឯកសារខ្លះសរសេរថា មានស្តេច២អង្គបានត្រឡប់មកតាំងរាជធានីចតុមុខវិញ ក្នុងរយៈពេលខ្លី១-២ឆ្នាំ៖

- ព្រះពញាញោម រវាងគ.ស.១៦០០ឬ១៦០១(ក្រោយបាក់បែករាជធានីលង្វែក)

-ព្រះអង្គចន្ទទី២(ព្រះឧទ័យរាជាអង្គចន្ទ) រវាងគ.ស.១៨១៥ឬ១៨១៦(ព្រះអង្គសោយរាជ្យគ.ស.១៨០៦-១៨៣៤ នៅរាជធានីឧត្តុង្គ)។

## ៤-ក្រុងភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា

ឆ្នាំ១៨៦៧ ព្រះបាទនរោត្តមបានប្តូររាជធានីពីឧត្តុង្គមកតាំងនៅភ្នំពេញ បន្ទាប់ពីតាំងនៅទីនោះមួយរយៈ(ពីគ.ស.១៨៥៩ដល់១៨៦៧)។ ដូច្នេះ ពីគ.ស.១៤៣៤ ដែលព្រះបាទពញាយ៉ាត មកតាំងរាជធានីនៅភ្នំពេញជាលើកទី១ (ព្រះពញាយ៉ាតនិងព្រះរាជាក្រោយៗមានរយៈពេល៧៤ឆ្នាំ)ដល់១៨៦៧ មានរយៈពេលចន្លោះ៤៣៣ឆ្នាំ ហើយរាជធានីឧត្តុង្គមានព្រះរាជាតាំងនៅយូរជាងគេអស់២៤៧ឆ្នាំ (ពីព្រះបាទជ័យជេដ្ឋាទី២ដល់ព្រះបាទនរោត្តម)បើទោះបីក្នុងរយៈពេលនោះមានព្រះមហាក្សត្រមួយចំនួនបានទៅតាំងរាជធានីនៅកន្លែងផ្សេងៗរយៈពេលខ្លីៗអស់ប្រមាណ២០ឆ្នាំក៏ដោយ។

មុនការប្តូររាជធានីឆ្នាំ១៨៦៧ ភ្នំពេញជាមជ្ឈមណ្ឌលពាណិជ្ជកម្មមួយស្ថិតតាមដងទន្លេចតុមុខ មានប្រជាជនប្រហែល ១០ ០០០នាក់ ទាំងជនជាតិចិននិងយួន។ ក្រៅពីនេះ មានអ្នករស់នៅលើទឹកមួយចំនួនទៀត។

ការសម្រេចព្រះទ័យប្តូររាជធានីនេះ មានមូលហេតុសំខាន់ៗ៣គឺ ១-រាជធានីថ្មីឆ្ងាយពីសៀមជាងមុន។ ២-សកម្មភាពសេដ្ឋកិច្ចនៅតំបន់ទន្លេចតុមុខក៏មានអំណោយផលជាងនៅឧត្តុង្គ និងទី៣-នៅទីនោះ មានពួកបារាំងឡើងចុះទៅមកងាយស្រួលដល់ការទាក់ទងជាង។

កំណត់សំខាន់ៗមួយរបស់យើង គឺព្រះបាទពញាយ៉ាតបានតាំងរាជវាំងនៅខាងជើងផ្សារចាស់សព្វថ្ងៃ (ពេលនោះ ខណ្ឌដោយព្រែកមួយឈ្មោះ ព្រែកពាមផ្លុង មុំអគ្គនាយកដ្ឋានរតនាគារជាតិ ប្រៃសណីយ៍កម្ពុជា អគ្គិសនីកម្ពុជា...)។ សម័យតាំងរាជធានីភ្នំពេញលើកទី២ ព្រះបាទនរោត្តម គង់នៅរាជវាំងត្រង់ទីតាំងសព្វថ្ងៃ បន្ទាប់ពីតាំងបណ្តោះអាសន្ននៅខាងជើងវត្តឧណ្ណាលោម ទម្រាំវាំងថ្មីដែលចាប់ផ្តើមសង់ពេលនោះដែរ ហើយរួចរាល់ឆ្នាំ១៨៧០ ចំណែកពួកអាណាព្យាបាលបារាំងជ្រើសរើសយកទីតាំងចាស់របស់ព្រះបាទពញាយ៉ាត ដែលជាទីខ្ពស់ស្រាប់ជុំវិញវត្តភ្នំ។

ពីឆ្នាំ១៨៦៧មកដល់បច្ចុប្បន្នមានរយៈពេលប្រមាណ១៥០ឆ្នាំ រាជធានីយើងមានទីតាំងភូមិសាស្ត្រជាក់លាក់ ហើយមានតែមួយនិងគ្មានការផ្លាស់ប្តូរ ពីពេលនោះដល់ចប់ព្រះរាជាណាចក្រទី១(ឆ្នាំ១៩៧០) ព្រោះថាការបន្តរាជ្យជាបន្តបន្ទាប់របស់ព្រះមហាក្សត្រខ្មែរត្រូវបានរៀបរយតាំងពីក្រោមអាណាព្យាបាលបារាំង គ្មានការដណ្តើមរាជ្យឬការចែកទឹកដីគ្រប់គ្រង... និងបន្តពីឆ្នាំ១៩៧០រហូតមកទៀត ជាមួយនឹងព្រឹត្តិការណ៍សំខាន់ៗរបស់ខ្លួន។

ក្នុងរាជ្យព្រះបាទនរោត្តម(គ.ស.១៨៥៩-១៩០៤) ព្រឹត្តិការណ៍ដ៏សំខាន់មួយដែលជារបត់ក្នុងការគ្រប់-គ្រងប្រទេសកម្ពុជាតាំងពីសម័យដើមមក គឺអនុសញ្ញាបារាំង-ខ្មែរ ថ្ងៃ១៧ ខែមិថុនា ឆ្នាំ១៨៨៤ ដែលជាកំណែ-ទម្រង់ស៊ីជម្រៅដើម្បីពង្រឹងអំណាចអាណានិគមបារាំង ដោយដកអំណាចពីព្រះមហាក្សត្រ។

ផ្អែកតាមអនុសញ្ញានេះ អំណាចអាណានិគមបារាំងដែលពីមុនបានដាក់ឱ្យមានតំណាង ឬរ៉េស៊ីដង់-ហ្សេណេរាល់ ឬរ៉េស៊ីដង់ស៊ុបេរីយើ(ឈ្មោះតំណែងតាមដំណាក់កាលនីមួយៗ) ពីឆ្នាំ១៨៦៣ នៅអមមហាក្សត្រ

ខ្មែរត្រូវបានពង្រីកមួយកម្រិតថែមទៀត គឺនៅឆ្នាំ១៨៨៦ ពួកគេបង្កើតឱ្យមានរ៉េស៊ីដង់នៅភ្នំពេញ និងនៅតាមខេត្ត៤ជាលើកដំបូង(កំពត កំពង់ធំ ក្រចេះ និងពោធិ៍សាត់)។«រាជការរដ្ឋបាលក្រុង»ក៏ត្រូវបានបង្កើតឡើង ដូចមានសំណេរដើមក្នុងសៀវភៅភូមិសាស្ត្របរិច្ឆេទឋាន ក្រុងភ្នំពេញ បោះពុម្ពឆ្នាំ១៩៣០ ត្រង់ទំព័រ៤១សរសេរថា «លោករ៉េស៊ីដង់មែរ ជានាយកត្រួតត្រារាជការរដ្ឋបាលក្រុងនេះ មានក្រុមជុំនុំមួយ ហៅថា កុំមីស្យុងមុនីស៊ីប៉ាល់ ជួយធ្វើការផង ឯក្រុមជុំនុំនេះមានបួនដណ្តប់នាក់ដែលលោករ៉េស៊ីដង្គស៊ុប៉េរីយើរតាំងឲ្យធ្វើ គឺបារាំងសេស៨នាក់ ខ្មែរ៣នាក់ ចិន២នាក់ យួន១នាក់។»

ជាសន្និដ្ឋាន ពាក្យ«**ភ្នំពេញ**» ត្រូវបានប្រើសម្គាល់«**ក្រុង**»ពីពេលនោះឯង គឺ**ក្រុងភ្នំពេញ** បន្តពីពាក្យដែលប្រជាជនហៅកាត់ខ្លីពី«**ភ្នំដូនពេញ**» ហើយពាក្យជាភាសាបារាំងក៏សរសេរ **Phnom Penh** ដូចនេះរហូតមក។ ដូច្នេះ ពីទីតាំងភូមិសាស្ត្រជារាជធានីនៃព្រះរាជាណាចក្រកម្ពុជាដែលព្រះមហាក្សត្រគង់នៅ ត្រូវរៀបចំថ្មីទៅជាក្រុង:បង្កើតគណៈកម្មការក្រុង(កុំមីស្យុងមុនីស៊ីប៉ាល់)ក្រុងចែកជារដ្ឋបាលឃុំ(៦ឃុំ)មានរៀបចំផ្លូវតូចធំ និងដាក់ឈ្មោះសម្គាល់ និងតាំងកន្លែងធ្វើការរបស់ពួកអាណាព្យាបាលបារាំង «រ៉េស៊ីដង្គមែរ» គឺជាអភិបាលក្រុង...។ ក្រុងត្រូវបានរៀបចំដំបូងក្នុងវិសាលភាពដូចខាងក្រោម៖

- ខាងកើតទល់ទន្លេចតុមុខ
- ខាងលិចត្រឹមបឹងតេជោ(ផ្លូវព្រះមុនីវង្សសព្វថ្ងៃ)
- ខាងជើងទល់ព្រែកពោងពាយបន្សល់ពីសម័យព្រះបាទពញាយ៉ាត (សួនច្បារក្លួចកាណុងគល់ស្ពានជ្រោយចង្វាសព្វថ្ងៃ)
- ខាងត្បូងទល់ព្រែកតាកែវបន្សល់ពីសម័យព្រះបាទពញាយ៉ាត(សួនច្បារវិមានឯករាជ្យ និងខាងកើតសព្វថ្ងៃ)។

ក្នុងវិសាលភាពខាងលើនេះ ឈ្មោះផ្លូវទាំងអស់ត្រូវដាក់ជាឈ្មោះបារាំង ព្រោះបារាំងជាអ្នកគ្រប់គ្រងចាត់ចែងការងារក្នុងក្រុង លើកលែងតែផ្លូវជាប់ទន្លេដែលមាននាមព្រះនរោត្តមនិងព្រះស៊ីសុវត្ថិ ហើយនិងផ្លូវផ្សារសួន(ផ្លូវជាប់ខាងត្បូងព្រះរាជវាំងឈ្មោះផ្លូវឧកញ៉ាឈុនសព្វថ្ងៃ)។ មហាវិថីមានតែ១ទេ គឺមហាវិថី ឌូដា ដឺ ឡាគ្រេ ដែលជាមហាវិថីព្រះនរោត្តមសព្វថ្ងៃ(លោក ឌូដា ដឺ ឡាគ្រេ ជាអ្នកធ្វើការទាក់ទងរវាងព្រះមហាក្សត្រនរោត្តមនិងតំណាងបារាំង ដើម្បីចុះសន្ធិសញ្ញាអាណាព្យាបាលថ្ងៃ១១ សីហា ១៨៦៣ និងជាតំណាងប្រទេសបារាំងប្រចាំកម្ពុជាដំបូងគេ)។

ក្រុងភ្នំពេញត្រូវបានគ្រប់គ្រងដោយអភិបាលក្រុងជាជនជាតិបារាំងជាបន្តបន្ទាប់រហូតដល់ឆ្នាំ១៩៤១ ហើយអភិបាលក្រុងជាជនជាតិខ្មែរដំបូងគេ គឺឯកឧត្តម ញឹក ជូឡុង ដែលត្រូវបានតែងតាំងដោយសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា(ខែមេសា ឆ្នាំ១៩៤១ ព្រះអង្គត្រូវបានក្រុមប្រឹក្សាព្រះរាជបល្ល័ង្កជ្រើសតាំងជាព្រះមហាក្សត្រ)។

អំពីទីតាំងសាលាក្រុងដែលជាកន្លែងធ្វើការរបស់អភិបាលក្រុងបារាំង ក៏ត្រូវបានសាងសង់ពីសម័យនោះដែរ។ បច្ចុប្បន្នទីតាំងសារមន្ទីរព្រះព្ទសានរ័ន្ន (សម្ពោធខែមេសា ឆ្នាំ២០១៩) ស្ថិតនៅផ្លូវព្រះមហាក្សត្រិយានី កុសុមៈ(ផ្លូវលេខ១០៦ខាងជើងផ្សារចាស់ ជាផ្លូវជាប់ខាងជើងព្រែកពាមផ្លុងសម័យមុន) ជាអតីតទីតាំងសាលាក្រុងសម័យបារាំង ហើយត្រូវបានប្រើប្រាស់បន្តដល់សម័យសម្តេចព្រះ នរោត្តម សីហនុ។

ជាចុងក្រោយ ពីឈ្មោះវត្តភ្នំដូនពេញមកដល់ក្រុងភ្នំពេញជារាជធានី ទីតាំងវត្តភ្នំ ត្រូវបានជួសជុលនិងកែលម្អ៥លើក បន្តពីការកសាងដំបូងដោយដូនពេញ(ផ្ទាំងចារឹកនៅវត្តភ្នំ) ទើបមកដល់មានរូបរាងសង្ហា

ហើយត្រូវបានចាត់ថ្នាក់ជារមណីយដ្ឋានទេសចរណ៍វប្បធម៌ និងប្រវត្តិសាស្ត្រតែមួយនៃរាជធានីភ្នំពេញសព្វថ្ងៃ ផ្ទៀបនឹងវត្តភ្នំដើមស.វ.ទី២០តាមសំណេរដើមក្នុងសៀវភៅភូមិសាស្ត្របរិច្ឆេណថានឆ្នាំ១៩៣០នៅចុងបញ្ចប់នេះ៖

- គ.ស.១៤៣៤ ដោយព្រះបាទពញាយ៉ាត ពេលតាំងរាជធានីនៅចតុមុខ
- គ.ស.១៤៦៥ ព្រះបាទនរាយណ៍រាជាដែលសោយរាជ្យបន្តពីព្រះបិតានាមព្រះបាទពញាយ៉ាត(មានការលើកដីពូនបន្ថែមនិងកសាងចេតិយធំបញ្ចុះព្រះបរមធាតុព្រះបាទពញាយ៉ាត)
- គ.ស.១៨០៦ ព្រះអង្គចន្ទទី២(ព្រះឧទ័យរាជាអង្គចន្ទ) គ.ស.១៨០៦-១៨៣៤ រាជធានីឧត្តុង្គ (មកតាំងរាជធានីនៅចតុមុខ រវាងគ.ស.១៨១៥ឬ១៨១៦)
- គ.ស.១៨៩៤ ព្រះមហាក្សត្រ ព្រះបាទនរោត្តម
- គ.ស.១៩២៦ ព្រះមហាក្សត្រ ព្រះបាទស៊ីសុវត្ថិ

«វត្តភ្នំមានកម្ពស់២៧ម. គិតទាំងវិហារនិងចេតិយ ហើយមានសួនច្បារនៅជុំវិញ។ ព្រះវិហារបែរមុខទៅទិសខាងកើត និងមានជណ្តើរទូលាយល្អប្រពៃដែលទើបនឹងរៀបចំឡើងវិញ ហើយមានរូបនាគ រូបតោ និងរូបពស់តុបតែងតាំងពីក្បាលជណ្តើរ ខាងក្នុងព្រះវិហារ មានក្រាលឥដ្ឋពណ៌យ៉ាងល្អ ហើយមានព្រះពុទ្ធរូបធំគង់លើរតនបល្ល័ង្កនិងមានក្បាច់រចនារំលេចយ៉ាងប្រពៃ ព្រមទាំងទិព្វមាសផង។ នៅក្រោយវិហារ មានចេតិយធំកំពូលស្រួចនិងទិព្វមាស។ នៅជើងទេរភ្នំ មានសួនច្បារតាក់តែងដោយផ្លូវខ្វាត់ខ្វែងចុះភ្ជាប់ទៅផ្លូវធំជុំវិញភ្នំ។ ក្នុងសួនមានដាំដើមឈើល្អនិងមានទ្រុងសត្វព្រៃគ្រប់យ៉ាងដែលមានក្នុងព្រះនគរទុកឲ្យអ្នកស្រុកមើលផង។ នៅលើសួនមានស្មៅកាត់ត្រឹមល្អ។ វេលាល្ងាចត្រជាក់ គេទៅលេងនៅទីនោះដើម្បីយកខ្យល់អាកាស ជាទីស្ងាត់កម្រមានសូរសព្ទអ្វី មានតែក្មេងដែលទៅលេងសប្បាយស្រែកឮសូរខ្សៀវខ្សាម្តងៗ។»

**កំណត់សម្គាល់**

១-ស្បូវភ្លាំងជាប្រភេទស្បូវម៉្យាងមានស្លឹកធំ ប្រើការសម្រាប់ប្រក់ផ្ទះ។

២-ស្រុកលាវជាឈ្មោះពីសម័យមុនដែលខ្មែរហៅប្រទេសឡាវ។

៣-ចៅហ្វាយស្រុកជាពាក្យសម្រាប់តំណែងអ្នកគ្រប់គ្រងខេត្តហើយចៅហ្វាយស្រុកខ្លះមានងារជាឧកញ៉ា។ចៅហ្វាយស្រុកមានសក្តិធំដែលគ្រប់គ្រងច្រើនខេត្ត ហៅស្តេចត្រាញ់ គឺជាមេទ័ពធំ ជាមួយនឹងងារខ្ពស់ៗរបស់ខ្លួនម្នាក់ៗថែមទៀត ដូចជាអ្នកឧកញ៉ាអជ៊ុន(ហៅក្លាយថា អរជូន) ខេត្តត្បូងឃ្មុំ ក្នុងរឿងទុំទាវជាដើម។

៤-ពាមជាកន្លែងដែលផ្លូវទឹកជួបគ្នា (ព្រែកពាមផ្លុង)។

*ដោយ បណ្ឌិតសភាចារ្យ ឆយ អូន*

## ១- បច្ចេកសព្ទប្រវត្តិវិទ្យា

| | |
|---|---|
| ១-កាលបរិច្ឆេទ | ការកំណត់ពេល ការកំណត់នៃថ្ងៃខែឆ្នាំ។ eng. date |
| ២-កាលប្បវត្តិ | ដែលរៀបតាមលំដាប់កាល។ eng. chronological |
| ៣-កាលវិទ្យា | ការសិក្សាអំពីលំដាប់នៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ។ ផ្នែកទាំងគូនៃប្រវត្តិវិទ្យា គឺកាលវិទ្យានិងភូមិវិទ្យា។ eng. chronology |
| ៤-កាលសម័យ | រយៈពេលមួយនៃប្រវត្តិសាស្ត្រដែលវែងជាងសម័យ។ eng. period |
| ៥-កាលសម័យបុរេប្រវត្តិ | កាលសម័យដែលផ្ដើមពីការកកើតមនុស្សលើផែនដីប្រហែល៥លានឆ្នាំមុននិងបញ្ចប់ដោយការបង្កើតអក្សរប្រហែលជាង៥ ០០០ឆ្នាំ កន្លងទៅ។ ឧ.ប្រទេសអេហ្ស៊ីប និងមេសូប៉ូតាមីឆ្លងផុតពីកាលសម័យបុរេប្រវត្តិនៅឆ្នាំ៣០០០មុនគ.ស.។ eng. prehistoric times |
| ៦-កាលសម័យប្រវត្តិសាស្ត្រ | ដំណាក់កាលនៃប្រវត្តិសាស្ត្រចាប់ពីមនុស្សចេះប្រើអក្សរ និងរក្សាទុកឯកសារសរសេរ។ eng. historic times |
| ៧-គ្រិស្តសករាជ | ការកំណត់ឆ្នាំចាប់ពីកំណើតព្រះយេស៊ូគ្រិស្ត(គ.ស.)។ eng. anno domini(A.D.) ,common era(C.E.) |
| ៨-ចុល្លសករាជ | សករាជតូច។ ការរាប់ឆ្នាំចាប់ពីថ្ងៃដែលព្រះបាទបទុមសុរិយវង្សបានកំណត់ទុកចាប់ពីថ្ងៃចន្ទ ១២កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ១១៨៣។ eng. lesser era |
| ៩-ទសវត្ស | រយៈកាល១០ឆ្នាំឬមួយខួបដប់ឆ្នាំ(មានន័យថា រយៈកាល១០ឆ្នាំម្ដងៗ)។ eng. decade |
| ១០-នវសម័យ | ដំណាក់កាលនៃប្រវត្តិសាស្ត្រចាប់ពីគ.ស.១៤៩២ឬ១៥០០រហូតដល់បដិវត្តន៍បារាំងឆ្នាំ១៧៨៩ឬដល់បច្ចុប្បន្ន(គ.ស.១៤៩២គ្រីស្តូហ្វ កូឡុំ រកឃើញទ្វីបអាមេរិក)។ eng. modern times |
| ១១-បុនសម័យ | ដំណាក់កាលនៃប្រវត្តិសាស្ត្រចន្លោះស.វ.ទី១៤និងទី១៧នៃគ.ស. តាមរយៈការរស់ឡើងវិញនៃតម្លៃវប្បធម៌អឺរ៉ុប និងការលេចឡើងនូវគំនិតភ្លឺស្វាង (ទស្សនវិជ្ជាពន្លឺ) របស់ទស្សនវិទូនៅអឺរ៉ុប។ eng. renaissance |
| ១២-បុរេប្រវត្តិសាស្ត្រ | កាលសម័យមុនមានឯកសារសរសេរ។ eng. prehistory |
| ១៣-ប្រវត្តិសាស្ត្រ | កម្រងនៃចំណេះដឹងដែលកត់ត្រានិងវិភាគព្រឹត្តិការណ៍អតីតកាល។ eng. history |
| ១៤-ពុទ្ធសករាជ | ការកំណត់ឆ្នាំចាប់ពីក្រោយថ្ងៃដែលព្រះពុទ្ធបរិនិព្វានទៅបានមួយថ្ងៃ(ព.ស.)។ eng. buddhist era |

១៥-មជ្ឈិមសម័យ ដំណាក់កាលនៃប្រវត្តិសាស្ត្រសាកលលោកចាប់ពីគ.ស.៥០០រហូតដល់គ.ស.១៥០០។ eng. middle age

១៦-មហាសករាជ សករាជធំ។ការរាប់ឆ្នាំចាប់ពីថ្ងៃសម្តេចព្រះអរិដ្ឋពលពាហនោ ( ព្រះកេតុមាលា ) បានកំណត់ទុកក្នុងពុទ្ធសករាជ៦២១ ត្រូវនឹងគ្រិស្តសករាជ៧៨។ eng. great era

១៧-មុនគ្រិស្តសករាជ ការកំណត់ឆ្នាំមុនកំណើតព្រះយេស៊ូគ្រិស្ត ( មុនគ.ស. )។ eng. before Christ ( B.C. ), before the common era ( B.C.E. )

១៨-យុគ ចន្លោះពេលនៃកាលភូគព្ភសាស្ត្រ ( យុគទឹកកក យុគថ្ម យុគលោហៈ )។ eng. age

១៩-ស័ក កាលសម័យភូគព្ភសាស្ត្រប្រមាណ៥៤០លានឆ្នាំកន្លងទៅនៃផែនដី ចាប់ពីកំណកំណើត។ ស័កត្រូវបានចែកជាបួន គឺស័កទី១ ហៅស័កមច្ឆជាតិ ស័កទី២ ហៅស័កដាយណូស័រ ស័កទី៣ ហៅស័កថនិកសត្វ និងស័កទី៤ ដែលផ្តើមពី២,៦លានឆ្នាំកន្លងទៅ។ ស័កទី៤ មានលក្ខណៈសម្គាល់ដោយការកើតឡើងនូវហូមីនីដ ( Hominids ) ជាថនិកសត្វទ្វេបាទ និងជាបុព្វបុរសរបស់មនុស្សសព្វថ្ងៃ។ eng. era

២០-សករាជ សម័យឬស័កដែលកើតមានបុគ្គលឬហេតុអស្ចារ្យណាមួយ។ ឧ.សករាជម៉ីជី ( Ere Meiji ) នៅប្រទេសជប៉ុន ចន្លោះគ.ស.១៨៦៨និង១៩១២។ eng. era

២១-សតវត្ស រយៈកាល១០០ឆ្នាំឬមួយខួបរយឆ្នាំ ( មានន័យថា រយៈកាល១០០ឆ្នាំម្តងៗ )។ eng. century

២២-សម័យ រយៈពេលមួយនៃប្រវត្តិសាស្ត្រដែលមានព្រឹត្តិការណ៍ពិសេសឬការប្រែប្រួលណាមួយកើតឡើង។ ឧ.សម័យសាធារណរដ្ឋខ្មែរចាប់ផ្តើម បន្ទាប់ពីព្រឹត្តិការណ៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ eng. epoch

២៣-សហសម័យ ដំណាក់កាលនៃប្រវត្តិសាស្ត្រចាប់ពីគ.ស.១៧៨៩ ( បដិវត្តន៍បារាំង ) ឬពីគ.ស.១៩១៧ ( បដិវត្តន៍ខែតុលា ) ដល់បច្ចុប្បន្ន។ eng. contemporary epoch

២៤-សហស្សវត្ស រយៈកាល១០០០ឆ្នាំឬមួយខួបពាន់ឆ្នាំ ( មានន័យថារយៈកាល១ ០០០ឆ្នាំម្តងៗ )។ ឧ.ប្រវត្តិសាស្ត្រកម្ពុជាចាប់ផ្តើមនៅដើមសហស្សវត្សទី១នៃគ្រិស្តសករាជ។ eng. millennum

២៥-អ៊ិស្លាមសករាជ ការកំណត់ឆ្នាំចាប់ពីថ្ងៃដែលមហាម៉ាត់រត់គេចពីក្រុងឡាម៉ិច ( La Mecque ) ទៅក្រុងមេឌីន ( Medine ) នៅគ.ស.៦២២ នាខែកក្កដា។

២៦-ឯកសារគ ឯកសារដែលគ្មានការកត់ត្រាជាលាយលក្ខណ៍អក្សរ ដូចជា ក្អម ឆ្នាំង និងវត្ថុសិល្បៈផ្សេងទៀត។ eng. non-written record

២៧-ឯកសារសរសេរ ឯកសារជាលាយលក្ខណ៍អក្សរដែលកត់ត្រានូវហេតុការណ៍និងព្រឹត្តិការណ៍នានាទុកជាចំណេះដឹង។ ឧ.សិលាចារឹកជាប្រភេទឯកសារសរសេរ។ eng. written record

# ២- ស្វែងយល់ពីប្រវត្តិមនុស្សខ្មែរ

ព្រះរាជាណាចក្រកម្ពុជា ជាផែនដីមួយចំណែកនៃប្រទេសអាស៊ីភាគអគ្នេយ៍ បានដល់ភូមិភាគប្រទេស វៀតណាម លាវ សៀម ខ្មែរ ដែលមានសណ្ឋានដូចជាដៃលូកចូលទៅក្នុងមហាសាគរប៉ាស៊ីហ្វិក។ នៅត្រង់មុំទិសអគ្នេយ៍នៃទ្វីបអាស៊ីនេះ មានជួរភ្នំច្រើនជាប់តមកពីភ្នំហិមាល័យ ហើយបត់ទៅខាងត្បូងប្រទេសចិន មានទ្រង់ទ្រាយរីកធំដូចផ្លិតបើក។ តាមចន្លោះកំពូលភ្នំទាំងនេះ មានខ្ពង់រាប និងស្នាប់ព្រៃធំជាទីឋានដែលមេទឹកធំតែងនាំយកល្បាប់មកចាក់ នាំឱ្យដីមានជីវជាតិ គឺទន្លេក្រហម ទន្លេមេគង្គ ទន្លេមេណាម ទន្លេសាលូអង់ និងទន្លេឥរាវឌី។ មេទឹកទាំងនេះ ខ្លះកាន់យកប្រភពនៅតំបន់ហិមពាន្ត ខ្លះទៀតនៅតំបន់យូណាន ហើយហូរចុះទៅកាន់សមុទ្រចិនខ្លះ សមុទ្រឥណ្ឌាខ្លះ។ មេទឹកទាំងនេះហើយដែលជាមេកសាងដីសណ្តរ ហើយបង្កើតបានឧបទ្វីបនៅអាស៊ីភាគអគ្នេយ៍នេះឡើង។ នៅតាមដងទន្លេទាំងនេះ មានមនុស្សច្រើនក្រុមអាស្រ័យ។ ព្រះរាជា-ណាចក្រកម្ពុជា ឋិតនៅទិសទក្សិណប្រទេសលាវ ទន្លេមេគង្គហូរកាត់ពាក់កណ្តាល ពីខាងជើងទៅខាងត្បូង ទីនេះមានបាតុភូតនៃធម្មជាតិមួយដ៏ចម្លែកអស្ចារ្យដែលមិនធ្លាប់កើតមានហើយធ្វើឱ្យជាប់ជានិស្ស័យក្នុងជីវិតមនុស្សនៅលើផែនដី គឺប្រទេសខ្មែរយើងនេះ កាលដើមឡើយជាឈូងសមុទ្រទឹកប្រៃ ចេញបាត់ទៅកើតបានជាទឹកដីមានជីវជាតិមួយល្អ ចិញ្ចឹមកូនចៅខ្មែរ(កម្ពុ) ឱ្យរស់នៅមាន កេរ្តិ៍ឈ្មោះរហូតមក ដូចសេចក្តីប្រាកដក្នុងសិលាចារឹកប្រាសាទប្រាំល្វែងចែងទុកថា៖ « ព្រះវររាជបិតា នៃព្រះរាជកុមារគុណវរ្ម័ន ដែលជាព្រះចន្ទនៃវង្សកៅណ្ឌិន្យ យកទឹកដីនេះបានពីទឹក »។ ផែនដីភូមិភាគនេះ មានជីវជាតិល្អមឱ្យមនុស្សរស់នៅបានយូរលង់ណាស់មកហើយ តាំងពីកាលមុនប្រវត្តិសាស្ត្រ គេអាចប្រមាណបានថា មានមនុស្សជាតិមកអាស្រ័យនៅពីក្នុងឆ្នាំ៦០០.០០០ មកដល់ឆ្នាំ១២.០០០ មុនគ្រីស្តសករាជ។ មានមនុស្សចូលមកអាស្រ័យនៅតាំងពីកាលទីឋាននៅជាកោះនៅឡើយ ដូចជាកោះជ្វាជាដើម គឺតាំងតែពីកាលមុនបុរាណសម័យ ( Pléistocène ) ដែលគេហៅថា ( Pithécantropus robustus ) ឬហៅថា យុគបុរាណសិលា ( Paléolithique )ក៏បាន ព្រោះគេបានរកឃើញឧបករណ៍បុរាណនៅអាស៊ីអាគ្នេយ៍នេះ ដូចជាកាំបិតចែតឬកាំបិតប៉ាំងតោដែលធ្វើអំពីថ្មគ្រើមជាដើម។ កាលបុរាណសម័យឆ្នាំ១២.០០០ មុនគ្រីស្តសករាជ ឧបករណ៍ដែលធ្វើពីថ្មមានការចម្រើនបន្តិចហើយ។ តមកទៀត នៅចន្លោះឆ្នាំ១២.០០០ មកដល់ ៨.០០០ មុនគ្រីស្តសករាជ គ្រឿងឧបករណ៍ ដូចជាកាំបិតចែតជាដើមប្រសើរប្លែកជាងកាលពីមុនហើយ ព្រោះសម័យនេះចូលមកក្នុងយុគថ្មីមួយទៀត ដែលហៅថា យុគនវសិលា ( Neolithique )។នៅចន្លោះឆ្នាំ៨.០០០មកដល់៣.០០០មុនគ្រីស្តសករាជវប្បកម្មគ្រឿងឧបករណ៍ឈានចូលមកក្នុងយុគមួយទៀតដែលហៅថាយុគមជ្ឈសិលា ( Mésolithique ) ព្រោះឃើញគ្រឿងឧបករណ៍រលីងមានមុខមុត គួរនឹងឱ្យយល់ថា ការវិវឌ្ឍន៍នេះកើនឡើងដោយសារមានវិត្ថារកម្មនៃមនុស្សជាតិថ្មីមួយក្រុមមកដល់ទៀត គឺកុលសម្ពន្ធ ម៉េឡាណេស៊ី( Me´lanésie ) ដែលផ្សេងពីជនស្បែកខ្មៅនៅទ្វីបអាហ្វ្រិក។ ឯវិត្ថារកម្មនៃក្រុមជនម៉េឡាណេស៊ីនេះ មានពីរលើកមកពីទិសខាងជើង ទៅទិសខាងត្បូងគឺ:

ក- លើកទីមួយ មនុស្សមានមាឌតូច ពណ៌ស្បែកខ្មៅ មានការចេះដឹងតមកពីក្រុមជន អូស្ត្រូ ឡូអ៊ីដ ( Austroloïde ) ដែលរលាយចូលទៅជាជាតិជាមួយគ្នា។ គ្រឿងឧបករណ៍នៃជនពួកនេះឃើញមាននៅប្រទេស

តុងកឹង តាមដងទន្លេក្រហម និងប្រទេសចម្ប៉ា គឺវៀតណាមកណ្តាល។ គេបានឃើញលលាដ៍ក្បាលជនម៉េឡាណេស៊ី ដែលផ្សំចូលគ្នាជាមួយលលាដ៍ក្បាលនៃជន អូស្រ្តូ ឡូអ៊ីដ នៅគុហា ឡាំង កៅ (Lang - Kao)។ កុលសម្ពន្ធនេះបានចូលមកដល់ប្រទេសលាវ (ក្រុងហ្លួងព្រះបាង - សាំនឿ) ប្រទេសសៀម ប្រទេសម៉ាឡេស៊ី (កេឡាន់តាន់ និង ប៉េរាក់)។

ខ- លើកទីពីរ កុលសម្ពន្ធម៉េឡាណេស៊ីមានមាឌធំ ពណ៌ស្បែកខ្មៅ សក់កង្ហាញ់រលក ពួកនេះលាយលោហិតចូលជាមួយជនអូស្រ្តូឡូអ៊ីដទៀត ព្រោះគេសង្កេតឃើញលលាដ៍ក្បាលនៃជនម៉េឡាណេស៊ីលើកទីពីរនេះ ផ្សំចូលគ្នាជាមួយលលាដ៍ក្បាលនៃជនដែលមកកាលពីលើកទីមួយ។ ក្រុមនេះប្រើគ្រឿងឧបករណ៍ដូច ជា ប៉ូវថៅថ្មខ្លីរលីង ហើយមានមុខមុត ហើយចេះប្រើខ្សែងនិងឆ្អឹងជាអាវុធ ព្រមទាំងចេះធ្វើចានថែមទៀត។ គេចាត់ទុកថាគ្រឿងឧបករណ៍ទាំងនេះនៅក្នុងយុគនវសិលា។ឯគ្រឿងទាំងនេះគេបានរកឃើញនៅតំបន់បាក់សឺន(Bac Son) ក្នុងប្រទេសតុងកឹង និងនៅឧបទ្វីបរហូតទៅដល់ប្រទេសម៉ាឡេស៊ី និងប្រទេសឥណ្ឌូណេស៊ីទៀតផង។ នៅក្នុងសម័យតមក (៣.០០០ ឆ្នាំមុនគ្រឹស្តសករាជ) មានក្រុមជនមួយផ្សេងទៀតចូលមកដល់ គឺជនឥណ្ឌូណេស៊ី ក្រុមនេះទំនងជាមកពីប្រទេសចិនភាគខាងត្បូង ហើយមករលាយលោហិតចូលជាមួយជនអូស្រ្តូឡូអ៊ីដ និងម៉េឡាណេស៊ី ដែលមកអាស្រ័យនៅក្នុងភូមិភាគនេះ ហើយកាលពីសម័យមុន ព្រោះឃើញមានលលាដ៍ក្បាលផ្សំគ្នា ដូចលលាដ៍ក្បាលនៅ ផូ ប៊ិញ យ៉ា (Pho bing gia) និងនៅ កាវ ផាយ (Kao Phay) ជាដើម។ តមក ប្រហែលជាពួកនេះកាន់អំណាច ព្រោះមានការចេះដឹងខ្ពស់ជាងក្រុមនៅ ផូ ញ៉ូ ក្វាង ( Pho nhoquang)។តែពួកនេះមិនសូវមានពូជពង្សតមកដល់សម័យបច្ចុប្បន្នកាលនេះដោយច្រើនទេមានតែពួកជនដែលមានទ្រង់ទ្រាយជាម៉េឡាណេស៊ីខ្លះ ដូចជាជន សេម៉ាង (Semang) នៅប្រទេសម៉ាឡេស៊ី ដែលគេទុកជាបាតសារវន្តនៃពូជមនុស្សជាតិនៅក្នុងប្រទេសម៉ាឡេស៊ី ហើយដែលមានវឌ្ឍនភាពរហូតមកដល់សព្វថ្ងៃនេះ។ គ្រឿងឧបករណ៍នៃជនពួកនេះ គេបានឃើញនៅលពបុរី រាជបុរី ក្នុងប្រទេសសៀម ហ្លួងព្រះបាង ក្នុងប្រទេសលាវប៉េរាក់ ក្នុងប្រទសម៉ាឡេស៊ី។ នៅរវាង ៣.០០០ឆ្នាំ មុនគ្រឹស្តសករាជ គេបានឃើញគ្រឿងឧបករណ៍យុគនវសិលាច្រើន មានបែបផ្សេងៗគ្នា នៅក្នុងឧបទ្វីបយើងនេះ។ ឯកុលសម្ព័ន្ធឥណ្ឌូណេស៊ី ដែលគេទុកជា (ស្តុក-សន្និធិ=stock)សារវន្តចូលមកនៅក្នុងភូមិភាគនេះពីរលើកគឺ៖ ១-ពួកចាមដើមមានក្បាលពយ ដងខ្លួនរាងក្រអាញនេះហើយជាវត្ថុធាតុបរមបុរាណបំផុតបានដល់កុលសម្ពន្ធជ្រាយរដែដែលមានទីលំនៅតាមខ្ពង់រាបភាគកណ្តាលនៃជួរភ្នំខាងកើតឧបទ្វីប។ ជនពួកនេះ មានទ្រង់ទ្រាយដូចពួកជន ទយ៉ាក់ (Dayaks) នៅកោះប៊័រណេអូ (Borne´o) និងជនអ៊ីគោរុត (Igorots) នៅកោះហ្វីលីពីន។ ២. ឯពួកចាមមកលើកក្រោយ មានក្បាលពយដែរតែមានភ្នែកតឹង ទំនងជាមានលាយលោហិតជាតិម៉ុងគោលផងចូលមកទីនេះតាមសមុទ្រ ហើយតាំងភូមិលំនៅតាមឆ្នេរសមុទ្រឧបទ្វីប បានដល់ ពួកចាម ម៉ាឡេ និង ជ្វា។ ទីបំផុត មានជាតិម៉ុងគោល ចូលមកទៀត ដែលយើងហៅថា កុលសម្ពន្ធថៃ ពួកដែលចូលមកនៅតាមដងទន្លេខៀវទៅជាថៃ ពួកដែលចូលមកនៅតាមដងទន្លេក្រហម ទៅជាវៀតណាម។ ឯកុលសម្ពន្ធមនុស្សជាតិ ដែលតាំងទីឋាននៅទិសនិរតីឧបទ្វីបអាស៊ីអគ្នេយ៍នេះ បានដល់ពួកជនឥណ្ឌូណេស៊ី និងជនម៉េឡាណេស៊ី ដែលរលាយជាតិរួមគ្នា ជាក្រុមមានចំនួនច្រើនជនជាតិនេះហើយ ជាដើមកំណើតពូជពង្សនៃកុលសម្ពន្ធខ្មែរ-មន ដែលបានតាំងភូមិលំនៅក្នុងភូមិភាគនេះ

ព្រមទាំងទីឋានដែលបិតនៅរហូតទៅដល់ព្រំប្រទល់ប្រទេសឥណ្ឌាភាគខាងកើត។ប្រជាជនមនបានតាំងទីឋាននៅភាគបស្ចឹមនៃឧបទ្វីប ឯប្រជាជនខ្មែរបានតាំងទីឋាននៅភាគបូព៌ានៃឧបទ្វីប ហើយកសាងជាប្រទេស ជាប្រជាជាតិរបស់ខ្លួន មានកេរ្តិ៍ឈ្មោះល្បីក្នុងសកលលោក រហូតមកដល់បច្ចុប្បន្នកាលនេះ។ បើនិយាយពីភាសាដែលជនទាំងនោះប្រើនិយាយ គួរយល់ថាប្រជាជនទាំងនោះ កាលដើមឡើយមានភាសាដើមរួមគ្នាតែមួយ គឺ អម្បូរភាសា ខ្មែរ-មន នេះឯង។ កុលសម្ពន្ធធំ គឺខ្មែរនិងមន។ កុលសម្ពន្ធតូចៗ មាននៅដេរដាសពាសពេញជ្រោយឧបទ្វីប ដូចជាកុលសម្ពន្ធ បាលូង ល្វា៉ា រៀង ខ្នុរ ឬ ឃ្នុរ តេង ឬ បេង ព្រូ ឬ ព្រៅ ស្រេ ព្រម ទាំង ជនព័រ ជង សំរែ កួយ ស្មៀង ភ្នង ឬក៏ ពហ្នា ម្នោង ម៉ាឡេស៍ ដែលហៅថា សេម៉ាង មុន្ទៈ ដែលនៅល្វសាន ប្រទេសឥណ្ឌា។ភាសានៃជនដូចពោលខាងលើនេះមានដូចគ្នាច្រើនណាស់គួររាប់ថាជាភាសាតែមួយបាន។មួយទៀត ភាសាខ្មែរ-មន នេះ ពុំមាននៅតែក្នុងឧបទ្វីបទេ មាននៅរហូតទៅដល់កោះធំ កោះតូច កណ្តាលមហាសាគរប៉ាស៊ីហ្វិក ដូចជាកោះហ្វីលីពីន ប៉័រណេអូ កោះជ្វា ស៊ូមាត្រាទៀត។ ប្រវត្តិការណ៍មានដូចពោលមកនេះ បានជាភាសាវិទូកត់ត្រាទុកថា «បើពោលដោយរួបរួមភាសានៃជនទាំងនេះ គួរហៅថា អម្បូរភាសាអូស្ត្រូ-អាស៊ី ( Austro – asiatique )។ ដូចជាយើងបានសិក្សាមកហើយ ប្រទេសយើងនេះជាឈូងសមុទ្រមួយធំ នៅឆ្នេរសមុទ្រ មានតែដីលិចទឹកមានមនុស្សជាតិមកអាស្រ័យនៅហើយតាំងពីសម័យមុនប្រវត្តិសាស្ត្រគឺកុលសម្ពន្ធខ្មែរ-មន។ កុលសម្ពន្ធខ្មែរ-មននេះ បានកសាងខ្លួនជាប្រជាជាតិមួយស្រេចមកហើយ មានអរិយធម៌របស់ខ្លួនមួយ មុនពីកាលដែលបានទទួលទុនអរិយធម៌( Apport ) ពីប្រទេសឥណ្ឌា។ នៅដែនដីយើងនេះ គេបានរកឃើញទីឋានដែលគេស្គាល់ថា ជាទីឋានមុនអរិយធម៌ឥណ្ឌាចូលមកដល់។ ទីឋាននេះ មានច្រើនកន្លែងដូចជា ទីឋានសំរោងសែន អន្លង់ផ្តៅ ម្លូព្រៃ ជាដើម ដែលកាលនោះសុទ្ធតែជាឆ្នេរសមុទ្រ ជាសក្ខីភាពនៃទីឋានមុនប្រវត្តិសាស្ត្រ ដែលគេហៅថា « Homo faber » មានសំបកខ្យងខ្ចៅ គ្រឿងឧបករណ៍ដែលធ្វើពីថ្មគ្រៀម ថ្មរលីង កុលាលភាជឆ្អឹងជាដើម។ លោក ម៉ាឡឺរេត៍ សរសេរថា កុលាលភាជនៅកំពង់ឆ្នាំង ដូចជានៅភ្នំក្រាំង ដីមាស ព្រៃគ្រី ក្រាំងកណ្តាល( ជិតព្រៃគ្រី ) ដែលនៅជិតកិវាចសំរោងសែន សុទ្ធតែធ្វើតាមបែបបុរាណ គួរយកបែបទាំងនេះមកទុកជាការសិក្សាសម្រាប់ឱ្យយល់បែបពីសម័យបុរាណ។ឯវិធីក្នុងយុគនវសិលាក៏មានទំនងប្រហែលគ្នាក្នុងសម័យយើងនេះដែរ។ ឆ្អឹងមនុស្សដែលគេបានរកឃើញនៅទីឋានទាំងនេះ គេឃើញថា ជនជាតិខ្មែរពីបុរាណ ជាមនុស្សមានមាឌធំមាំមួន ទម្រង់មុខមានចិញ្ចើមលាន ទ្រង់ទ្រាយសក្តិសម ហើយមានមុខរបររកស៊ីធ្វើនេសាទ ប្រមាញ់ ចិញ្ចឹមគោ ជ្រូក ព្រោះចេះធ្វើព្រួញពីឆ្អឹង ពីដែក ដូចជាសន្ទូច មូល ច្បូកជាដើម។ នៅម្លូព្រៃ គេបានរកឃើញកន្លែងស្លដែក ឬសម្រឹទ្ធពីបុរាណ ប៉ុន្តែគេមិនបានរកឃើញដំណែលទាំងនេះ ដែលគេហៅថា « Homo sapiens » នោះទេ គឺមិនឃើញមានរូបអក្សរ ឬអក្សររូបសត្វ។ គេអាចយល់នូវជីវភាពមនុស្សបុរាណនៅតំបន់ម្លូព្រៃសម័យមុនប្រវត្តិសាស្ត្របាន គឺកាលនោះ មនុស្សចេះធ្វើខ្ទម រោង ដោល នៅជិតគ្នា ពីមួយទៅមួយតាមដងស្ទឹង ដងអូរដែលហូរចុះទៅកាន់សមុទ្រ ឬទៅកាន់បឹង នៅលើគោកមានក្របីស៊ីស្មៅ តាមវាលស្រែមានជ្រូកនៅក្នុងទ្រុង ក្នុងរដូវប្រាំង អ្នកស្រុកដើរចេញរកបរបាញ់ នៅផ្ទះធ្វើព្រួញ មូល ច្បូក ស្ន ក្នុងរដូវទឹកឡើង អ្នកស្រុកចេះធ្វើទូកដែលខ្លួនចោះឈើដោយដឹងថ្ម ដើម្បីទៅធ្វើនេសាទ ចាស់ឬស្រីនៅផ្ទះធ្វើក្អមឆ្នាំង ហើយយកទៅហាលឱ្យស្ងួតសម្រាប់ទុកសាច់ឬត្រីនៅក្រោយផ្ទះស្ត្រីត្បាញសំពត់ឬភួយដោយសរសៃអំបោះ។

ជីវភាពបែបនេះមាននៅសល់ខ្លះ តាមជនបទចុងកាត់មាត់ញក ដែលអ្នកមកថ្មីទៅមិនដល់ ដូចជាទំនៀមធ្វើមង្គលកូនកើតការកូនឬក៏ប្រពៃណីខ្មោចជាដើម។គេបានឃើញសពមនុស្សដែលមានគ្រោងឆ្អឹងអង្គុយបញ្ឈរជង្គង់ ដៃពាក់កងសម្រឹទ្ធថ្ម ឬសំបកខ្យង ជាសពនាំឱ្យគេយល់ថា នេះជាពិធីតាំងសពបុរាណ បានសេចក្តីថាកាលនោះគេមិនប្រើវិធីដុតខ្មោចដូចកាលដែលជនជាតិឥណ្ឌាចូលមកដល់នោះទេ។នេះហើយជាជីវភាពមនុស្សដែលរស់នៅលើដែនដីយើងក្នុងសម័យមុនប្រវត្តិសាស្ត្រ គឺមុនអរិយធម៌ឥណ្ឌាចូលមកដល់។ ក្នុងកាលខាងដើមគ្រឹស្តសករាជ អ្នកបស្ចឹមប្រទេសយល់ថា ប្រទេសយើងមានអរិយធម៌ដុះដាលឃើតបន្តិច ប្រសិនបើប្រៀបធៀបទៅនឹងអរិយធម៌អឺរុបឥណ្ឌា-អឺរុបឬចិនហើយក្នុងកាលនោះអរិយធម៌អេស៊ីបត៍ឬមជ្ឈិមបូព៌ារលត់រលាយទៅហើយ ចំណែកខាងទ្វីបអឺរុបក្នុងសម័យ Pax Romana ក្រុងរ៉ូម កំពុងឡើងកាន់ឧទ្ធគ្គតភាព (Apoge´e)។ អ្នកប្រាជ្ញយល់ថា ក្នុងគ្រឹស្តសតវត្សទី១ មានជនហិណ្ឌូចូលមកកាន់ដែនដីអាស៊ីអាគ្នេយ៍ ហើយធ្វើពាណិជ្ជកម្មស្វះស្វែងរកភោគទ្រព្យឆើតគឺ មាស ពេជ្រ ឬគ្រឿងទេសគឺក្រវាញ ក្រកោ ដូង កាលនោះ មានគមនាគមន៍រវាងប្រទេសឥណ្ឌា និងប្រទេសអាស៊ីភាគអាគ្នេយ៍កើតឡើង ហើយជនហិណ្ឌូខ្លះមកអាស្រ័យនៅ នាំយកវប្បធម៌ហិណ្ឌូមកផ្សាយក្នុងកាលតមកកើតជាកូនពូនជាចៅហើយរលាយជាតិជាមួយអ្នកស្រុក។នេះហើយជាបុព្វហេតុដែលនាំឱ្យកើតរដ្ឋ ដែលហៅថា រដ្ឋកាន់អរិយធម៌ឥណ្ឌា (Etats Hindouise´s) បានដល់រដ្ឋចាម្ប៉ា ខ្មែរ មន ម៉ាឡេស៍ឥណ្ឌូណេស៊ីនៅភូមិភាគនេះឡើង។តែក្នុងសម័យកាលជាមួយគ្នានេះមិនមែនមានតែជនហិណ្ឌូមួយទេដែលមកនៅអាស្រ័យក្នុងទីនេះជនជាតិចិនក៏មកកាន់ទីនេះដែរមកនៅហើយកើតជាកូនពូនជាចៅរលាយចូលជាមួយអ្នកស្រុកដូចជនហិណ្ឌូទៀត។ ហេតុដូចពោលដោយសង្ខេបមកនេះ នាំ ឱ្យអ្នកប្រាជ្ញទូទៅចងជាពាក្យពោលថា៖ អរិយធម៌នៅអាស៊ីភាគអាគ្នេយ៍ ជាអរិយធម៌ដែលកើតឡើងដោយការផ្សំផ្គុំ គឺការផ្សំផ្គុំអរិយធម៌ឥណ្ឌា-ចិន ហើយកើតបានជាអរិយធម៌មួយនៅអាស៊ីភាគអាគ្នេយ៍នេះឡើង។ក្នុងសម័យដែលអរិយធម៌ឥណ្ឌាចូលមក គេឃើញថា រចនាសម្ពន្ធខាងសង្គមកិច្ច មិនបានប្រែប្រួលសភាពទៅ តាមសង្គមហិណ្ឌូទាំងអស់ទេ អ្នកស្រែចម្ការមិនមានឯកសិទ្ធិដូចអ្នកជាន់ខ្ពស់ឡើយ។ចំណោរចីរកាលតមកប្រជាជនខ្មែរបានទទួលយកវប្បធម៌ឥណ្ឌា គឺសាសនាព្រាហ្មណ៍ ពុទ្ធសាសនា និងវិជ្ជាការគ្រប់ជំពូក។ មានអ្នកខ្លះយល់ខុសថា កាលជនហិណ្ឌូចូលមកដល់ទឹកដីយើងកាលនោះ គេបានឃើញសុទ្ធតែមនុស្សព្រៃ អ្នក ទាំងផ្តាស់យល់ដូច្នេះខុសស្រឡះទេ។ តាមការពិត ប្រទេសខ្មែរយើងមានអរិយធម៌ជារបស់ខ្លួនហើយ មាន ទំនងដូចជនអាយ៌នចូលមកដល់ទឹកដីឥណ្ឌា បានឃើញរដ្ឋវាសី (Autochtone) ដែលហៅជនដ្រាវិឌជាអ្នក មានសេចក្តីចម្រើនជាងខ្លួនដូច្នោះដែរ ព្រោះប្រជាជនខ្មែរយើងកាលនោះ មានសេចក្តីចម្រើនដូចប្រទេសទាំងឡាយ ដែលនៅអាស៊ីភាគអាគ្នេយ៍ទាំងអស់ជាប្រទេសមូស្សុង (Pays des moussons)។

**អក្សរសិល្ប៍ប្រជាប្រិយខ្មែរ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ថុង**

## ជីវភាពមនុស្ស ( ពាក្យ៧ )

បឋម កុលបុត្រនៃខ្មែរថ្មី ខិតខំឃ្នាតខ្មីរកចំណេះ
វ័យ ត្រូវស្វាធ្យាយឱ្យបានចេះ កែខៃតម្រិះឱ្យល្អក្រៃ។
ត្រូវ ប្រឹងទន្ទេញប្រៀនប្រាជ្ញា ប្រិតប្រៀងឧស្សាហ៍រាល់យប់ថ្ងៃ
ខំ ហាត់សំភីយកថ្វីដៃ ឱ្យបានជោគជ័យក្នុងមុខងារ។
រៀន សព្វវិជ្ជាគ្រូបង្ហាត់ យល់គ្រប់សង្កាត់វគ្គល្បះឃ្លា
សូត្រ សាឡើងវិញឱ្យច្រើនគ្រា គ្រប់រាល់ទិវារាត្រីអើយ។
មជ្ឈិម ជាពេលចាកសាលា អូសអង្គអាត្មាមកកៀកកើយ
វ័យ ចូលប្រឡូកជីវិតហើយ គួរធ្វើម្ដេចឡើយប្រសើរជាង។
បញ្ញត្តិ ចាត់ថាកាត់លោភោ មោហោទោសោនិងឆន្ទា
ថា មិនចង់បានខុសធម្មា នាំមានកម្មពៀរគ្រោះអស់ជន្ម។
ឱ្យខំ ធ្វើការដោយទៀងត្រង់ ខិតខំផ្ចិតផ្ចង់ចិត្តឱ្យធ្ងន់
រកស៊ី មានបានខាងទ្រព្យធន តាមរូបមន្តពុទ្ធោវាទ។
ចិញ្ចឹម គ្រួសារឱ្យថ្កើងថ្កាន វេលាដែលបានកុំប្រមាទ
ជីវិត មនុស្សលោកតែងសស្អាត ត្រិះរិះសង្វាតរាប់ព្រាងលាន។
មច្ឆិម ពេលនេះជ្រៀងជ្រេរហើយ កុំនៅតោះតើយតោងធ្វើទាន
វ័យ ចាស់ជរាកុំបំពាន កាន់ធូបកាន់ទៀនទៅវត្តអ៊ា។
ពុទ្ធានុញ្ញាត ឱ្យបំបាត់ កិលេសសូន្យថ្វាត់បង់អសារ
ឱ្យខំ ធ្វើបុណ្យកុំរអា តាមពុទ្ធសាសនាជាបច្ច័យ។
សន្សំ ដាក់បាត្រចំណីស្បៀង ហើយកាត់រំលាងកងក្ខមក្ខ័យ
សីលទាន ធ្វើហើយកុំអាល័យ ឱ្យចាកទុក្ខភ័យរាគតណ្ហា។

សួនកំណាព្យ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង

## រឿងកំណើតស្រូវ (ទេវកថា)

កាលពីព្រេងនាយមនុស្សយើងមិនបាច់ត្រូវការដាំច្រូតកាត់ដឹកជញ្ជូនស្រូវទេ គឺស្រូវដុះពាសវាលពាសកាលហើយវាចេះហោះមកចូលជង្រុកដោយខ្លួនឯងទាំងគ្មានសំបកទៀតផង។ ប៉ុន្តែមានថ្ងៃមួយ ស្ត្រីកំណាចម្នាក់បានវាយស្រូវនឹងបន្ទះក្តារ ដោយមកពីនាងនោះថ្លង់នឹងស្នូរស្រូវហោះចូលជង្រុកផ្ទះនាង។ តាំងពីពេលនោះមក ស្រូវក៏រត់ទៅពួននៅកណ្តៀតថ្មភ្នំយ៉ាងជ្រៅ។ មនុស្សម្នាកើតក្តីខ្វល់ខ្វាយគ្រប់ៗគ្នា ដោយមិនដឹងរកអ្នកណាទៅហៅស្រូវឱ្យមកវិញបាន។ គេប្រជុំគ្នាដើម្បីជ្រើសរើសរកអ្នកស្ម័គ្រចិត្តបំពេញតួនាទីនេះ។ ពេលនោះ មានត្រីស្លាតមួយក្បាល ដោយអាណិតមនុស្សខ្លាំងពេកបានស្ម័គ្រយកអាសារឿងនេះ ។ វាប្រឹងហែលលូនត្បូលតាមកណ្តៀតថ្ម នៅទីបំផុតក៏បានជួបនឹងមេស្រូវ។ ត្រីស្លាតបានសុំអង្វរករមេស្រូវឱ្យវិលត្រឡប់ទៅជួយសង្គ្រោះមនុស្សលោកវិញ។

មេស្រូវបានយល់ព្រមតាមសេចក្តីអង្វរកររបស់ត្រីស្លាត ប៉ុន្តែបាននិយាយទៅកាន់ត្រីស្លាតថាៈ

« អំណិះតទៅស្រូវមិនហោះចូលជង្រុកដូចមុនទៀតទេ បើចង់បានស្រូវត្រូវភ្ជួររាស់ដកស្ទូងហើយស្រូវដុះតែក្នុងរដូវភ្លៀងតែប៉ុណ្ណោះ។ត្រីស្លាតត្រឡប់មកវិញនាំដំណឹងនេះមកប្រាប់មនុស្ស ហើយទាំងអស់គ្នាមានសេចក្តីត្រេកអរក្រៃលែង។

ចំណាំ : ត្រីស្លាតមានដងខ្លួនសំប៉ែត ក៏ដោយសារមកពីត្បូលននៀលតាមក្រហែងថ្ម។ រហូតមកដល់សព្វថ្ងៃនេះនៅមានតំបន់ខ្លះកាលណាគេប្រារព្ធពិធីសែនមេស្រូវគេតែងថ្វាយត្រីស្លាតឆ្អើរមួយក្រាស់។ប្រសិនបើពិនិត្យទៅលើតំណរយៈកាលវិកលូតលាស់របស់សង្គមមនុស្ស គឺជាតំណាក់កាលចាប់ផ្តើមមានកំណើតកសិកម្មនៅក្នុងសង្គមបុព្វកាល។របៀបរស់នៅដោយពឹងផ្អែកលើធម្មជាតិទាំងស្រុង លែងរស់បានទៀតហើយ ពីព្រោះធម្មជាតិត្រូវបានប្រើប្រាស់ដោយចំនួនមនុស្សកាន់តែច្រើន បរិមាណកាន់តែថយចុះ ទើបឈានចូលដល់សករាជដាំដុះចិញ្ចឹមសត្វ។



ប្រាសាទត្រពាំងផុង



ពហុកីឡាដ្ឋានជាតិមរតកតេជោ